# កិច្ចព្រមព្រៀងទិញលក់ទឹកដំុ

**រវាង**

**[ឈ្មោះ]**
(«**អ្នកផ្តល់សេវាលក់ទឹកដំុ** »)

**និង**

**[ឈ្មោះ]**
(«**អ្នកផ្តល់សេវាលក់ទឹករាយ**»)

**ធ្វើនៅកាលបរិច្ឆេទ ______________២០២២**

# មាតិកា


**១. ការបកស្រាយន័យពាក្យ-ឃ្លាឃ្លោងមួយចំនួន ............ ៥**
**២. ថិរវេលាសុពលភាពនៃកិច្ចព្រមព្រៀង ............ ៦**
២.១. ថិរវេលា............ ៦
២.២. ការបញ្ចប់............ ៦
**៣. កាតព្វកិច្ចរបស់អ្នកផ្តល់សេវាលក់ទឹកដុំ ............៦**
៣.១. ផ្គត់ផ្គង់ទឹក ............ ៦
៣.២. ទទួលការបង់ប្រាក់ ............ ៦
៣.៣. មិនផ្តល់ទឹកផ្គត់ផ្គង់ទៅប្រភពផ្សេង ............ ៦
**៤. កាតព្វកិច្ចរបស់អ្នកផ្តល់សេវាលក់ទឹកស្អាតរាយ............ ៦**
៤.១. ទទួលទឹក ............ ៦
៤.២. បង់ប្រាក់ ............ ៦
៤.៣. ការអនុញ្ញាតអោយរាយទុយោ ............ ៧
៤.៤. មិនទទួលទឹកផ្គត់ផ្គង់ពីប្រភពផ្សេង ............ ៧
**៥. កាតព្វកិច្ចរួមគ្នារបស់គូភាគី ............ ៧**
៥.១. កិច្ចសហការគ្នា ............ ៧
៥.២. ការពិនិត្យវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀង ............ ៧
**៦. ការផ្គត់ផ្គង់ទឹកធ្វើប្រព្រឹត្តិកម្មរួច ............ ៨**
៦.១. ប្រភពទឹក ............ ៨
៦.២. កាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ ............ ៨
៦.៣. ការប្រគល់ និងការទទួលទឹកត្រូវផ្គត់ផ្គង់ ............ ៨
៦.៤. ការវាស់វែង ............ ៨
៦.៥. ការផ្តល់ព័ត៌មាន និងការត្រួតពិនិត្យ ............ ៩
**៧. បរិមាណទឹក ............ ១០**
៧.១. បរិមាណអប្បបរមា និងអតិបរមា ............ ១០
៧.២. កាតព្វកិច្ចប្រគល់ទឹក និងបង់ថ្លៃទឹក ............ ១០
**៨. សម្ពាធទឹក និងចរន្តហូរទឹក ............ ១០**
៨.១. សម្ពាធទឹកសម្រាប់ប្រតិបត្តិការធម្មតា ............ ១០
៨.២. ការខកខានរក្សាសម្ពាធទឹក និងចរន្តហូរទឹកតាមកម្រិតសេវាកម្មព្រមព្រៀង ............ ១០
**៩. គុណភាពទឹក ............ ១០**
៩.១. ស្តង់ដាគុណភាពទឹក ............ ១០

**១០. ការខកខានធ្វើតាមលក្ខខណ្ឌតម្រូវ ........ ១១**
១០.១. ការខកខានរបស់អ្នកផ្តល់សេវាលក់ទឹកដុំ ........ ១១
១០.២. ប្រាក់ពិន័យសំណងដែលអ្នកផ្តល់សេវាលក់ទឹកដុំត្រូវបង់ ........ ១១
**១១. តំហែទាំ ........ ១១**
១១.១. តំហែទាំ ........ ១១
១១.២. ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំតាមការគ្រោងទុក........ ១២
១១.៣. ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំដែលមិនបានគ្រោងទុកមុននិងហេតុការណ៍បន្ទាន់........ ១៣
**១២. ការបង់ប្រាក់ ........ ១៣**
១២.១. ប្រាក់កក់ ........ ១៤
១២.២. ថ្លៃសេវាកម្ម ........ ១៤
១២.៣. វិក្កយបត្រ ........ ១៥
១២.៤. លក្ខខណ្ឌបង់ប្រាក់ ........ ១៥
១២.៥. ពន្ធ ........ ១៥
១២.៦. ការបង់ប្រាក់យឺត ........ ១៥
១២.៧. វិក្កយបត្រមានវិវាទ ........ ១៥
១២.៨. ការកែតម្រូវវិក្កយបត្រ ........ ១៦
**១៣. ការបង់សំណង ........ ១៦**
១៣.១. ការបង់សំណងរបស់អ្នកផ្តល់សេវាលក់ទឹកដុំ........ ១៦
១៣.២. ការបង់សំណងរបស់អ្នកផ្តល់សេវាលក់ទឹកស្អាតរាយ........ ១៧
១៣.៣. វិធីបង់សំណង ........ ១៧
**១៤. ប្រធានសក្តិ ........ ១៨**
១៤.១. ហេតុការណ៍ប្រធានសក្តិ ........ ១៨
១៤.២. ការព្យួរកាតព្វកិច្ច ........ ១៩
១៤.៣. ដំណោះស្រាយពេលកើតមានប្រធានសក្តិ ........ ១៩
១៤.៤. ការកាត់បន្ថយផលប៉ះពាល់ ........ ១៩
**១៥. ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀង ........ ១៩**
១៥.១. ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្តល់សេវាលក់ទឹកដុំ........ ១៩
១៥.២. ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្តល់សេវាលក់ទឹកស្អាតរាយ........ ២០
**១៦. ការបញ្ចប់កិច្ចព្រមព្រៀង ........ ២០**
១៦.១. ការបញ្ចប់កិច្ចព្រមព្រៀង ........ ២០
១៦.២. វិធីបញ្ចប់កិច្ចព្រមព្រៀង ........២០
១៧. ការជូនដំណឹង ........ ២១

១៧.១. ការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ........ ២១
១៧.២. ព័ត៌មានសម្រាប់ប្រាស្រ័យទាក់ទង-ជូនដំណឹង ........ ២២
១៧.៣. ការផ្លាស់ប្តូរព័ត៌មានសម្រាប់ប្រាស្រ័យទាក់ទង-ជូនដំណឹង ........ ២២
១៧.៤. ការជូនដំណឹងជាភាសាខ្មែរ ........ ២២
**១៨. ច្បាប់គ្រប់គ្រង និងការដោះស្រាយវិវាទ ........ ២២**
១៨.១. ច្បាប់គ្រប់គ្រង ........ ២២
១៨.២. ការដោះស្រាយវិវាទ ........ ១៩
**១៩. បញ្ញត្តិផ្សេងទៀត ........ ២៣**
១៩.១. ភាពសម្ងាត់ ........ ២៣
១៩.២. ភាពអាចផ្តាច់ពីគ្នានៃបញ្ញត្តិកិច្ចព្រមព្រៀង ........ ២៤
១៩.៣. វិសោធនកម្ម ........ ២៤
១៩.៤. ការបោះបង់សិទ្ធិ ........ ២៤
១៩.៥. អនុប្បទាន ........ ២៤
១៩.៦. ការស្នងបន្តកិច្ចព្រមព្រៀង ........ ២៤
១៩.៧. កិច្ចព្រមព្រៀងទាំងមូល ........ ២៤
ឧបសម្ព័ន្ធទី១ - និយមន័យ ........ ២៧
ឧបសម្ព័ន្ធទី២ - ចំណុចប្រគល់ ........ ៣២
ឧបសម្ព័ន្ធទី៣ - បរិមាណ ........ ៣៣
ឧបសម្ព័ន្ធទី៤ - សម្ពាធទឹក និងចរន្តហូរទឹក ........ ៣៤
ឧបសម្ព័ន្ធទី៥ - គុណភាពទឹកត្រូវផ្គត់ផ្គង់ ........ ៣៥
ឧបសម្ព័ន្ធទី៦ - ថ្លៃលក់ទឹក ........ ៣៦
ឧបសម្ព័ន្ធទី៧ - ស្តង់ដាកុងទ័រ និងឧបករណ៍ផ្សេងទៀត ........ ៣៧

# កិច្ចព្រមព្រៀងទិញលក់ទឹកជុំ

កិច្ចព្រមព្រៀងទិញលក់ទឹកជុំនេះ («កិច្ចព្រមព្រៀង») ធ្វើនៅ [កាលបរិច្ឆេទ] («កាលបរិច្ឆេទចាប់មានអានុភាព») រវាង ៖

(១) [ឈ្មោះអ្នកផ្តល់សេវាលក់ទឹកជុំ] ដែលជាក្រុមហ៊ុនបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដោយមានលេខបញ្ជិកានៅក្រសួងពាណិជ្ជកម្ម [លេខ] និងមានការិយាល័យចុះបញ្ជីនៅ [អាសយដ្ឋាន] («**អ្នកផ្តល់សេវាលក់ទឹកជុំ**») និង

(២) [ឈ្មោះអ្នកផ្តល់សេវាទឹកស្អាតរាយ] ដែលជាក្រុមហ៊ុនបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដោយមានលេខបញ្ជិកានៅក្រសួងពាណិជ្ជកម្ម [លេខ] និង មានការិយាល័យចុះបញ្ជីនៅ [អាសយដ្ឋាន] («**អ្នកផ្តល់សេវាទឹកស្អាតរាយ**»)។

(អ្នកផ្តល់សេវាលក់ទឹកជុំ និង អ្នកផ្តល់សេវាទឹកស្អាតរាយ សម្គាល់ហៅរៀងខ្លួនថា «**ភាគី**» និងរួមគ្នាថា «**គូភាគី**»)។

## បុព្វកថា

ក. អ្នកផ្តល់សេវាលក់ទឹកជុំ បានទទួល [អាជ្ញាប័ណ្ណផ្គត់ផ្គង់ទឹក] ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវនុវត្តន៍ (MISTI) ដើម្បីផ្គត់ផ្គង់ទឹកឆៅ និង/ឬទឹកស្អាតដែលបានធ្វើប្រព្រឹត្តិកម្មរួចជូនបណ្តាអ្នកផ្តល់សេវាទឹកស្អាតរាយ ចែកចាយបន្តនៅក្នុងតំបន់នៃដែនអាជ្ញាប័ណ្ណរបស់អ្នកផ្តល់សេវាលក់ទឹកជុំ។ អាជ្ញាប័ណ្ណផ្គត់ផ្គង់ទឹកនេះមានលេខបញ្ជិកា [លេខ] [កាលបរិច្ឆេទចេញអាជ្ញាប័ណ្ណ]។

ខ. អ្នកផ្តល់សេវាទឹកស្អាតរាយបានទទួល [អាជ្ញាប័ណ្ណចែកចាយទឹក] ពី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវនុវត្តន៍ (MISTI) ហើយខ្លួនមានសមត្ថកិច្ចផ្គត់ផ្គង់ទឹកស្អាត ជូនដល់អតិថិជននៅក្នុងតំបន់នៃដែនអាជ្ញាប័ណ្ណរបស់ខ្លួន។ អាជ្ញាប័ណ្ណចែកចាយទឹកនេះមានលេខបញ្ជិកា [លេខ] [កាលបរិច្ឆេទចេញអាជ្ញាប័ណ្ណ]។

គ. អ្នកផ្តល់សេវាលក់ទឹកជុំ មានបំណងផ្គត់ផ្គង់ និង លក់ ទឹកជុំតាមកិច្ចព្រមព្រៀង ជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ហើយអ្នកផ្តល់សេវាទឹកស្អាតរាយ មានបំណងទទួលយក និង ទិញ ទឹកជុំតាមកិច្ចព្រមព្រៀងពីអ្នកផ្តល់សេវាលក់ទឹកជុំ ។

**ដោយហេតុដូច្នេះ គូភាគីបានព្រមព្រៀងគ្នាដូចតទៅ ៖**

## ១. ការបកស្រាយន័យពាក្យ-ឃ្លាឃ្លោងមួយចំនួន

ពាក្យ-ឃ្លាឃ្លោងជាអក្សរខ្មៅដិត ឬ ស្ថិតនៅក្នុងវង់ក្រចក ឬ សញ្ញាធ្មេញកណ្តុរ នៅក្នុងកិច្ចព្រមព្រៀងនេះត្រូវមានន័យដូចកំណត់ក្នុង**ឧបសម្ព័ន្ធទី១ (និយមន័យ)**។

## ២. ថិរវេលាសុពលភាពនៃកិច្ចព្រមព្រៀង

### ២.១. ថិរវេលា

ថិរវេលាសុពលភាពនៃកិច្ចព្រមព្រៀងនេះ ចាប់ផ្តើមរាប់ពីកាលបរិច្ឆេទចាប់មានអានុភាព រហូតដល់កាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀង។

### ២.២. ការបញ្ចប់

កិច្ចព្រមព្រៀងនេះត្រូវបញ្ចប់ ស្របតាមខ្លឹមសារនៃប្រការ១៦ (ការបញ្ចប់កិច្ចព្រមព្រៀង)។

## ៣. ភារកិច្ចរបស់អ្នកផ្តល់សេវាលក់ទឹកដុំ

### ៣.១. ផ្គត់ផ្គង់ទឹក

អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវផ្គត់ផ្គង់ទឹកជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ស្របតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ៖

៣.១.១. <u>ប្រភពទឹក</u> ៖ ពីប្រភពដូចកំណត់ក្នុងប្រការ ៦.១. (ប្រភពទឹក)។

៣.១.២. <u>ចំណុចប្រគល់</u> ៖ នៅចំណុចប្រគល់ដូចកំណត់ក្នុងឧបសម្ព័ន្ធទី២ (ចំណុចប្រគល់)។

៣.១.៣. <u>បរិមាណ</u> ៖ ក្នុងបរិមាណដូចកំណត់ក្នុងប្រការ ៧ (បរិមាណ)។

៣.១.៤. <u>សម្ពាធទឹក និងចរន្តហូរទឹក</u> ៖ តាមកម្រិតសម្ពាធទឹក និងចរន្តហូរទឹកដូចកំណត់ក្នុងប្រការ៨ (សម្ពាធទឹក និងចរន្តហូរទឹក)។

៣.១.៥. <u>គុណភាព</u> ៖ ក្នុងគុណភាពដូចកំណត់ក្នុងប្រការ ៩ (គុណភាពទឹក)។

### ៣.២. ទទួលការបង់ប្រាក់

អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវទទួលប្រាក់ទូទាត់ ឬការប្រាក់ ដែលអ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវបង់ជូនខ្លួន ស្របតាមខ្លឹមសារនៃប្រការ ១២ (ការទូទាត់ប្រាក់)។

### ៣.៣. មិនផ្តល់ទឹកផ្គត់ផ្គង់ទៅប្រភពផ្សេង

អ្នកផ្តល់សេវាលក់ទឹកដុំយល់ព្រមថា ប្រសិនគ្មានការយល់ព្រមជាលាយល័ក្ខណ៍អក្សររបស់អ្នក ផ្តល់សេវាលក់ទឹកស្អាតរាយទេនោះ ខ្លួននឹងមិនលក់ទឹកទៅអោយអ្នកប្រើប្រាស់ទឹកនៅតាមផ្ទះ តាមអាជីវកម្ម ឬ ភាគីទីបីណាមួយដែលស្ថិតនៅក្នុងតំបន់ផ្តល់សេវាកម្មដែលបានកំណត់នៅក្នុងអាជ្ញាប័ណ្ណរបស់អ្នកផ្តល់សេវាទឹកស្អាតរាយនោះឡើយ។

## ៤. ភារកិច្ចរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ

### ៤.១. ទទួលទឹក

អ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវទទួលយកទឹកដុំ ពីអ្នកផ្តល់សេវាលក់ទឹកដុំ ស្របតាមប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

### ៤.២. បង់ប្រាក់

អ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវបង់ប្រាក់ទូទាត់ និងការប្រាក់ ជូនអ្នកផ្តល់សេវាទឹកដុំ តាមការកំណត់គណនា និងចេញវិក្កយបត្រដូចមានចែងក្នុងប្រការ ១២ (ការទូទាត់ប្រាក់)។

### ៤.៣. ការអនុញ្ញាតអោយរាយទុយោ

ដោយហេតុថាវាជាការចាំបាច់ក្នុងការអនុវត្តតាមកិច្ចព្រមព្រៀងនេះ អ្នកផ្តល់សេវាទឹកស្អាតរាយបានយល់ព្រមថាខ្លួននឹងអនុញ្ញាតអោយអ្នកផ្តល់សេវាលក់ទឹកដុំអាចរាយទុយោនៅក្នុងតំបន់ផ្តល់សេវាកម្មរបស់អ្នកផ្តល់សេវាទឹកស្អាតរាយដូចដែលបានកំណត់នៅក្នុងអាជ្ញាប័ណ្ណរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ។

### ៤.៤. មិនទទួលទឹកផ្គត់ផ្គង់ពីប្រភពផ្សេង

អ្នកផ្តល់សេវាទឹកស្អាតរាយយល់ព្រមថា ក្នុងអំឡុងប្រាំឆ្នាំដំបូងនៃថិរវេលាសុពលភាពនៃកិច្ចព្រមព្រៀងនេះ ប្រសិនគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកផ្តល់សេវាទឹកដុំទេនោះ ខ្លួននឹងមិនជាវទឹកពី ភាគីទីបីណាមួយឡើយ ហើយខ្លួនក៏នឹងមិនជីកស្រះ ដែរ លើកលែងតែករណីដែលអ្នកផ្តល់សេវាលក់ទឹកដុំ ខ្លួនឯង មិនអាចផ្គត់ផ្គង់ទឹកជូនអ្នកផ្តល់សេវាទឹកស្អាតរាយក្នុងបរិមាណមួយដែលលើសបរិមាណ អតិបរមាតាមការស្នើសុំរបស់អ្នកផ្តល់សេវាទឹកស្អាតរាយបាន។

## ៥. ភាតព្វកិច្ចរួមគ្នារបស់គូភាគី

### ៥.១. កិច្ចសហការគ្នា

ភាគីនីមួយៗឯកភាពថានឹងសហការគ្នា និងប្រាស្រ័យទាក់ទងគ្នាដើម្បីធ្វើយ៉ាងណាអនុវត្តកិច្ចព្រមព្រៀងនេះឲ្យមានប្រសិទ្ធភាព។ ចំណុចជាកម្មវត្ថុនៃកិច្ចសហការគ្នានេះរួមមានជាអាទិ៍ ៖

(ក) សម្របសម្រួលរៀបចំកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ

(ខ) រៀបផែនការទុកជាមុនសម្រាប់ដោះស្រាយហេតុការណ៍បន្ទាន់នានា

(គ) ដោះស្រាយបញ្ហាប្រឈមនានាដែលអាចកើតមានទាក់ទងនឹងការតម្រូវរបស់ច្បាប់ថ្មីៗ

(ឃ) សម្រួលយ៉ាងណាឲ្យភាគីនីមួយៗអាចបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ និងកាតព្វកិច្ចកិច្ចសន្យានានារបស ខ្លួនបាន

(ង) កាត់បន្ថយឲ្យដល់កម្រិតអប្បបរមានូវហានិភ័យលើបុគ្គល សម្ភារៈ និងបរិស្ថានដែលអាចកើតមានទាក់ទងនឹងប្រតិបត្តិការផ្គត់ផ្គង់ទឹកតាមកិច្ចព្រមព្រៀងនេះ និង

(ច) សហការគ្នាដើម្បីធានាថា ទឹកដែលផ្គត់ផ្គង់ជូនអ្នកប្រើប្រាស់មានគុណភាពស្របតាមស្តង់ដាបច្ចេកទេស ដែលកំណត់ដោយMISTI។

### ៥.២. ការពិនិត្យវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀង

គូភាគីត្រូវធ្វើការពិនិត្យវាយតម្លៃការអនុវត្តកិច្ចព្រមព្រៀងនេះ ក៏ដូចជាឧបសម្ព័ន្ធនានារបស់វា យ៉ាងហោចណាស់មួយដងជារៀងរាល់ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ ដើម្បីកំណត់ថា តើវាពិតជាឆ្លើយតបនឹងការរៀបចំ និងស្ថានភាពប្រតិបត្តិការនានាដែលកំពុងអនុវត្ត និងបានគ្រោងនឹងអនុវត្ត ក៏ដូចជាចំណុចដទៃទៀត

ដែលគូភាគីបានឯកភាពគ្នាដែរឬទេ។ គូភាគីត្រូវដាក់របាយការណ៍ស្តីពីព័ត៌មានដូចខាងក្រោមនេះជូនគ្នាទៅវិញទៅមកយ៉ាងហោចណាស់ឲ្យបានមួយសប្តាហ៍មុនចាប់ផ្តើមជំនួបពិនិត្យវាយតម្លៃប្រចាំឆ្នាំរបស់ខ្លួន ៖

(ក) ចំណុចថាតើភាគីនីមួយៗបានបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងនេះដែរឬទេ (៤. ការផ្គត់ផ្គង់ និងទទួលទឹក)។

(ខ) ការប្រែប្រួលតម្រូវការទឹក និងគុណភាពទឹកដែលផ្គត់ផ្គង់រៀងរាល់ថ្ងៃ និងរៀងរាល់ខែ។

(គ) ភាពសំបូរបែបនៃបរិមាណទឹករបស់ប្រភពទឹក។

(ឃ) គម្រោងពង្រីកប្រព័ន្ធផលិតកម្មនិងបណ្តាញទុយោចែកចាយទឹករបស់អ្នកផ្តល់សេវាទឹកស្អាតរាយ។

(ង) គម្រោងធ្វើតំហែទាំជួលជុល នៅឆ្នាំខាងមុខរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ ។

(ច) គម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់របស់អ្នកផ្តល់សេវាលក់ទឹកដុំ ។

(ឆ) គម្រោងធ្វើតំហែទាំជួលជុល នៅឆ្នាំខាងមុខរបស់អ្នកផ្តល់សេវាលក់ទឹកដុំ ។

(ជ) បញ្ហានានាដែលអាចបង្កផលប៉ះពាល់លើការអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀងនេះរបស់ភាគីនីមួយៗ។

ប្រសិនភាគីណាមួយចង់ឲ្យមានការប្រជុំបន្ទាន់មួយនៅមុនកាលកំណត់នៃ ជំនួបពិនិត្យវាយតម្លៃប្រចាំឆ្នាំនេះ ភាគីនោះអាចធ្វើការកោះប្រជុំនោះបាន តាមរយៈការជូនដំណឹងភាគីមួយទៀតជាលាយល័ក្ខណ៍អក្សរ។

## ៦. ការផ្គត់ផ្គង់ទឹកស្អាតដែលបានធ្វើប្រព្រឹត្តិកម្មរួច

### ៦.១. ប្រភពទឹក

អ្នកផ្តល់សេវាទឹកដុំ ជាភាគីទទួលខុសត្រូវក្នុងការទាញយកទឹកឆៅពី ទន្លេសាបដើម្បីយកមកធ្វើប្រព្រឹត្តកម្មនៅស្ថានីយ៍ផលិតកម្មរបស់ខ្លួន។

### ៦.២. កាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ

គូភាគីឯកភាពគ្នាថា ភាគីនីមួយៗអាចត្រូវការបញ្ចប់ការសាងសង់មួយចំនួនសិនមុនពេលខ្លួនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចព្រមព្រៀងនេះបាន។ ភាគីនីមួយៗត្រូវផ្តល់ដំណឹងជូនភាគីមួយទៀតជាប្រចាំពីកាលបរិច្ឆេទគ្រោងបញ្ចប់ការសាងសង់របស់ខ្លួន។ បន្ទាប់ពីការសាងសង់ចប់សព្វគ្រប់ គូភាគីត្រូវព្រមព្រៀងគ្នាកំណត់កាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ។

### ៦.៣. ការផ្គត់ផ្គង់ និងការទទួលយកទឹកត្រូវផ្គត់ផ្គង់

រាប់ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការរហូតដល់កាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀង អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវផ្គត់ផ្គង់ទឹកដុំ ជូនអ្នកផ្តល់សេវាទឹកស្អាតរាយ នៅចំណុចប្រគល់ ។

### ៦.៤. ការវាស់វែង

៦.៤.១.<u>កុងទ័រ និងឧបករណ៍វាស់</u> ៖ ដើម្បីកំណត់បរិមាណទឹក (ប្រការ ៧) សម្ពាធទឹក និងចរន្តហូរទឹក (ប្រការ៨) និងគុណភាពទឹក (ប្រការទី៩) រាល់ការវាស់វែងត្រូវធ្វើនៅចំណុចប្រគល់។ អ្នកផ្តល់

សេវាលក់ទឹកដុំ ជាភាគីរ៉ាប់រងចំណាយដំឡើង ធ្វើតេស្ត និងថែទាំកុងទ័រទឹក ឧបករណ៍វាស់សម្ពាធទឹក និងឧបករណ៍វាស់ចរន្តរំហូរទឹកនៅចំណុចផ្គត់ផ្គង់-ទទួលយក។

៦.៤.២.ស្តង់ដាកុងទ័រ និងឧបករណ៍វាស់ ៖ បទដ្ឋានបច្ចេកទេស (ដូចជាប្រភេទនាឡិកាទឹក) និងវិធីសាស្ត្រវិភាគលំអៀង នាឡិកាទឹក ឧបករណ៍វាស់សម្ពាធទឹក និងឧបករណ៍វាស់ចរន្តរំហូរទឹក គឺកំណត់នៅក្នុងឧបសម្ព័ន្ធទី៧ (ស្តង់ដានាឡិកាទឹក និងឧបករណ៍វាស់ផ្សេងទៀត)។

## ៦.៥. ការបើកទូលាយ និងការត្រួតពិនិត្យ

៦.៥.១.ការបើកទូលាយ ៖ អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ ត្រូវអនុញ្ញាតឲ្យអ្នកផ្តល់សេវាទឹកស្អាតរាយ ពិនិត្យមើលនាឡិកាទឹក និងឧបករណ៍វាស់សម្ពាធទឹកភ្លាម ហើយក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីមានសំណើជាលាយល័ក្ខណ៍អក្សរមកកាន់ខ្លួន អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ ត្រូវផ្តល់ទិន្នន័យទាក់ទងនឹងលទ្ធផលវាស់វែងទាំងអស់របស់នាឡិកាទឹក និងឧបករណ៍វាស់សម្ពាធទឹកជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ដើម្បីផ្ទៀងផ្ទាត់ថាតើវាត្រឹមត្រូវតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះដែរឬទេ។

៦.៥.២.ការដំឡើងឧបករណ៍បន្ថែម ៖ អ្នកផ្តល់សេវាទឹកស្អាតរាយ អាចចេញចំណាយផ្ទាល់ខ្លួនដើម្បីដំឡើងនាឡិកាទឹក ឧបករណ៍វាស់សម្ពាធទឹក និងឧបករណ៍វាស់ចរន្តរំហូរទឹករបស់ខ្លួនបន្ថែមលើបរិក្ខារមានស្រាប់របស់អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ ដែលស្ថិតនៅចន្លោះ [លេខ] ម៉ែត្រ ជៀបនឹង នៅចំណុចផ្គត់ផ្គង់-ទទួលយក ដើម្បីឲ្យប្រាកដថាប្រតិបត្តិការធ្វើឡើងស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។

៦.៥.៣.សវនកម្ម ៖អ្នកផ្តល់សេវាទឹកស្អាតរាយ មានសិទ្ធិទាមទារឲ្យធ្វើសវនកម្មលើនាឡិកាទឹក ឧបករណ៍វាស់សម្ពាធទឹក និង/ឬឧបករណ៍វាស់ចរន្តរំហូរទឹកដើម្បីឲ្យប្រាកដថាវាដំណើរការត្រឹមត្រូវ ដោយគ្រាន់តែខ្លួនជូនដំណឹងអ្នកផ្គត់ផ្គង់សេវាទឹកដុំ ជាលាយល័ក្ខណ៍អក្សរតាមបែបបទកំណត់ក្នុងប្រការ ៦.៤.១. (ការបើកទូលាយ) ខាងលើ។ អ្នកផ្តល់សេវាទឹកស្អាតរាយ ជាអ្នករ៉ាប់រងចំណាយទាំងអស់សម្រាប់ការធ្វើសវនកម្មនេះ លើកលែងករណីរកឃើញតាមរយៈសវនកម្មនេះថា នាឡិកាទឹក ឧបករណ៍វាស់សម្ពាធទឹក និង/ឬឧបករណ៍វាស់ចរន្តរំហូរទឹកមានភាពមិនប្រក្រតីដោយវាដើរលឿងក្នុងកម្រិត [លេខ]% ឬលើសនេះ។ អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ ត្រូវបង់រាល់ចំណាយជួសជុល ឬវិធីសាស្ត្រវិភាគលំអៀងនាឡិកាទឹក ឧបករណ៍វាស់សម្ពាធទឹក និង/ឬឧបករណ៍វាស់ចរន្តរំហូរទឹកដើម្បីឲ្យវាដើរស្រួលបួលឡើងវិញ។ ក្រៅពីនេះ អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ ត្រូវកែតម្រូវវិក្កយបត្រដែលអាចគិតខុសដោយសារលទ្ធផលវាស់វែងមិនត្រឹមត្រូវចេញពីឧបករណ៍ទាំងនោះ ស្របតាមខ្លឹមសារនៃប្រការ ១២.៩. (ការកែតម្រូវវិក្កយបត្រ) ខាងក្រោមនេះ។

# ៧. គុណភាពទឹក

## ៧.១. បរិមាណអប្បបរមា និងអតិបរមា

៧.១.១.<u>បរិមាណអប្បបរមា និងអតិបរមា</u> ៖ បរិមាណអប្បបរមា និងបរិមាណអតិបរមាគឺដូចកំណត់ក្នុងឧបសម្ព័ន្ធទី៣ (បរិមាណ)។ អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ យល់ព្រមផ្គត់ផ្គង់ទឹកជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ក្នុងបរិមាណមួយដែលមិនតិចជាងបរិមាណអប្បបរមា ហើយច្រើនរហូតដល់កម្រិតអតិបរមា។

៧.១.២.<u>កម្រិតប្រចាំថ្ងៃ</u> ៖ បរិមាណអប្បមាប្រចាំថ្ងៃសម្រាប់ខែនីមួយៗគឺដូចកំណត់ក្នុងឧបសម្ព័ន្ធទី៣ (បរិមាណ)។

### ៧.២. កាតព្វកិច្ចប្រគល់ទឹក និងបង់ថ្លៃទឹក

អ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវ ទិញ និង បង់ប្រាក់សម្រាប់បរិមាណអប្បបរមា សម្រាប់វិក្កយបត្រតាមខែនីមួយៗ ទោះខ្លួនមិនបានទិញដល់បរិមាណអប្បបរមាក៏ដោយ លុះត្រាណាអ្នកផ្តល់សេវាលក់ទឹកដុំ មានឆន្ទៈ និងលទ្ធភាពផ្គត់ផ្គង់បរិមាណអប្បបរមាប្រចាំថ្ងៃជូនខ្លួននៅ ចំណុចប្រគល់ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។

## ៨. សម្ពាធទឹក និងចរន្តហូរទឹក

### ៨.១. សម្ពាធទឹកសម្រាប់ប្រតិបត្តិការធម្មតា

ដោយត្រូវអនុលោមប្រការ ៨.២. ផងដែរនោះ (ការខកខានរក្សាសម្ពាធទឹក និងចរន្តហូរទឹក) អ្នកផ្តល់សេវាលក់ទឹកដុំត្រូវប្រឹងប្រែងឲ្យអស់ពីលទ្ធភាពរបស់ខ្លួនក្នុងការផ្គត់ផ្គង់ទឹកជូនអ្នកផ្តល់សេវាទឹកស្អាតរាយ នៅចំណុចប្រគល់ទៅតាមកម្រិតសម្ពាធទឹក និងចរន្តហូរទឹកដូចកំណត់ក្នុងឧបសម្ព័ន្ធទី៤ (សម្ពាធទឹក និងចរន្តហូរទឹក)។

### ៨.២. ការខកខានរក្សាសម្ពាធទឹក និងចរន្តហូរទឹក

គូភាគីទទួលស្គាល់ និងយល់ស្របថា ការណ៍ដែលអ្នកផ្តល់សេវាលក់ទឹកដុំ ខកខានរក្សាសម្ពាធទឹក និងចរន្តហូរទឹក វាមិនមែនជាការរំលោភបំពានកិច្ចព្រមព្រៀងនេះឡើយប្រសិនការខកខាននោះបណ្តាលមកពីហេតុការណ៍បន្ទាន់ណាមួយ។

## ៩. គុណភាពទឹក

### ៩.១. ស្តង់ដាគុណភាពទឹក

អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវផ្គត់ផ្គង់ទឹកដុំជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ស្របតាមស្តង់ដាគុណភាពទឹកដូចកំណត់ក្នុងឧបសម្ព័ន្ធទី៥ (គុណភាពនៃទឹកត្រូវផ្គត់ផ្គង់) នៅចំណុចប្រគល់។

## ១០. ការខកខានធ្វើតាមលក្ខខណ្ឌតម្រូវ

### ១០.១.ការខកខានរបស់អ្នកផ្តល់សេវាលក់ទឹកដុំ

ប្រសិន ៖

(ក) អ្នកផ្តល់សេវាលក់ទឹកដុំ ដឹងថា ខ្លួនខកខានបំពេញកាតព្វកិច្ចរបស់ខ្លួនដូចកំណត់ក្នុងប្រការ ៧ (បរិមាណទឹក) ប្រការ ៨ (សម្ពាធទឹក និងចរន្តហូរទឹក) ឬប្រការ ៩ (គុណភាពទឹក) នោះ អ្នកផ្តល់សេវាលក់ទឹកត្រូវជូនដំណឹងអ្នកផ្តល់សេវាទឹកស្អាតរាយភ្លាមអំពីការខកខាននោះ។ និង

(ខ) អ្នកផ្តល់សេវាទឹកស្អាតរាយ ដឹងពីការខកខានរបស់អ្នកផ្តល់សេវាលក់ទឹកដុំ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចកំណត់ក្នុងប្រការ ៧ (បរិមាណទឹក) ប្រការ៨ (សម្ពាធទឹក និងចរន្តហូរទឹក) ឬប្រការ ៩ (គុណភាពទឹក) នោះ អ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវជូនដំណឹងអ្នកផ្តល់សេវាលក់ទឹកដុំ ភ្លាមអំពីការខកខាននោះ។

ហើយអ្នកផ្តល់សេវាទឹកដុំ ត្រូវចាត់វិធានការចាំបាច់នានាដើម្បីសម្របតាមប្រការ៧ (បរិមាណទឹក) ប្រការ ៨ (សម្ពាធទឹក និងចរន្តហូរទឹក) ឬប្រការ ៩ (គុណភាពទឹក) ឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើបាន។

ក្នុងករណីដែលខកខានមិនអនុវត្តតាមប្រការ ៧ (បរិមាណទឹក) ឬ ប្រការ ៨ (សម្ពាធទឹក និងចរន្តហូរទឹក)ក្នុងអំឡុង [ប្រាំ (៥) ថ្ងៃ] បន្ទាប់ពីខ្លួនទទួលបានការជូនដំណឹង អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវជូនដំណឹងអ្នកផ្តល់សេវាទឹកស្អាតរាយវិញជាលាយល័ក្ខណ៍អក្សរអំពីចំណាត់ការដែលខ្លួននឹងដាក់ចេញដើម្បីកែតម្រូវស្ថានភាពនៃការខកខានរបស់ខ្លួនក្នុងការបំពេញលក្ខខណ្ឌតម្រូវ។

ក្នុងករណីដែលខកខានមិនអនុវត្តតាមប្រការ ៩ (គុណភាពទឹក) ក្នុងអំឡុង [មួយ (១) ថ្ងៃ] បន្ទាប់ពីខ្លួនទទួលបានការជូនដំណឹង អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវធ្វើរបាយការណ៍មួយជាលាយល័ក្ខណ៍អក្សរជូនអ្នកផ្តល់សេវាទឹកស្អាតរាយ អំពីចំណាត់ការដែលខ្លួននឹងដាក់ចេញដើម្បីកែតម្រូវស្ថានភាពនៃការខកខានរបស់ខ្លួនក្នុងការបំពេញលក្ខខណ្ឌតម្រូវ។

### ១០.២. ប្រាក់ពិន័យសំណងដែលអ្នកផ្តល់សេវាលក់ទឹកដុំត្រូវបង់

ក្នុងករណីអ្នកផ្តល់សេវាលក់ទឹកដុំ ខកខានមិនបានបំពេញកាតព្វកិច្ចណាមួយរបស់ខ្លួនដូចកំណត់ក្នុងប្រការ ៧ (បរិមាណទឹក) ប្រការ ៨ (សម្ពាធទឹក និងចរន្តហូរទឹក) ឬប្រការ ៩ (គុណភាពទឹក) នោះ អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវបង់ប្រាក់សំណង ចំនួន [ចំនួន] រៀលក្នុងមួយថ្ងៃដែលស្មើនឹងទំហំនៃការខូចខាតជារៀងរាល់ថ្ងៃរហូតដល់ពេលខ្លួនកែតម្រូវស្ថានភាពនៃការខកខានរបស់ខ្លួនក្នុងការបំពេញលក្ខខណ្ឌតម្រូវជូន អ្នកផ្តល់សេវាទឹកស្អាតរាយ ។

## ១១. តំហែទាំ

### ១១.១.តំហែទាំ

ភាគីនីមួយៗរ៉ាប់រងបន្ទុកគ្រប់គ្រង ប្រតិបត្តិ ថែទាំ ជានាសុវត្ថិភាព និងជួសជុលបរិក្ខាររបស់ខ្លួនរៀងខ្លួនចាប់ពីកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការដល់កាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀង។

## ១១.២.ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំតាមការគ្រោងទុក

១១.២.១. តំហែទាំតាមកាលវិភាគ ៖ ភាគីនីមួយៗត្រូវធ្វើតំហែទាំបរិក្ខាររបស់ខ្លួនរៀងខ្លួនតាមកាលវិភាគរៀបចំទុកមុនជាប្រចាំ រួមមាន ការជួសជុល ការផ្លាស់ប្តូរ កែលម្អ និងផ្លាស់ជំនួស ស្របតាមផែនការ និងកាលវិភាគធ្វើតំហែទាំដែលរៀបចំឡើងស្របតាមខ្លឹមសារនៃផ្នែកទី១១.២.នេះ (ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំតាមការគ្រោងទុក)។

១១.២.២. ការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ៖ លើកលែងមានការព្រមព្រៀងផ្សេងរបស់គូភាគី ភាគីម្ខាងត្រូវជូនដំណឹងភាគីម្ខាងទៀតជាលាយល័ក្ខណ៍អក្សរយ៉ាងហោចណាស់ [ហុកសិប (៦០)] ថ្ងៃជាមុនពីបំណងរបស់ខ្លួនក្នុងការជួសជុល ការផ្លាស់ប្តូរ កែលម្អ និងផ្លាស់ជំនួសបរិក្ខារដែលនឹងបង្កផលប៉ះពាល់ ឬរាំងស្ទះដំណើរការប្រក្រតីនៃការបញ្ជូនទឹកស្អាត។ (ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំតាមការគ្រោងទុក)។ លិខិតជូនដំណឹងនោះត្រូវបញ្ជាក់កាលបរិច្ឆេទ និងម៉ោងពេលកើតមានភាពរអាក់រអួល ក្នុងដំណើរការជាប្រចាំនៃការបញ្ជូនទឹកស្អាតនោះ។

១១.២.៣. ការសម្របសម្រួលគ្នា ៖ គូភាគីត្រូវរួមគ្នារៀបចំកាលវិភាគធ្វើតំហែទាំ ដើម្បីឲ្យការផ្អាកប្រតិបត្តិការដោយសារតែតំហែទាំងនោះកើតឡើងក្នុងពេលដំណាលគ្នាតាមដែលអាចធ្វើបាន។

១១.២.៤. កំហិតការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំតាមការគ្រោងទុក ៖ ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំតាមការគ្រោងទុកក្នុងឆ្នាំនីមួយៗនៃកិច្ចព្រមព្រៀងនេះមិនត្រូវប្រើពេលលើស [បញ្ចូល] ម៉ោងឡើយ។

១១.២.៥. ការផ្លាស់ប្តូរកាលវិភាគ ផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំ ៖ គូភាគីត្រូវបញ្ជាក់ពីគម្រោងនៃ ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំ ឲ្យបាន [ហុកសិប (៦០)] ថ្ងៃមុនដល់ថ្ងៃផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំ និងបញ្ជាក់សាជាថ្មីម្តងទៀតឲ្យបាន [ម្ភៃមួយ (២១)] ថ្ងៃមុនដល់ពេលធ្វើតំហែទាំនោះ។ ភាគីណាក៏ដោយអាចស្នើសុំផ្លាស់ប្តូរកាលវិភាគ ផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំ ដោយខ្លួនត្រូវបង្ហាញហេតុផលសមរម្យ ហើយភាគីមួយទៀតត្រូវខិតខំលៃលកយ៉ាងណាឆ្លើយតបនឹងការស្នើសុំនោះ។ ប្រសិនបើមិនអាចឆ្លើយតបនឹងសំណើនោះបាន ភាគីនោះត្រូវជូនដំណឹងភាគីមួយទៀតជាលាយល័ក្ខណ៍អក្សរឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន តែដោយមិនត្រូវយឺតជាង [ដប់ប្រាំ (១៥)] ថ្ងៃបន្ទាប់ពីខ្លួនបានទទួលសំណើផ្លាស់ប្តូរកាលវិភាគ ផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំ នោះឡើយ។

## ១១.៣. ការផ្អាកប្រតិបត្តិការ ដែលមិនបានគ្រោងទុកមុន និងហេតុការណ៍បន្ទាន់

១១.៣.១. ការផ្អាកប្រតិបត្តិការ ដែលមិនបានគ្រោងទុកមុន ៖ ប្រសិនបើកើតមានការផ្អាកប្រតិបត្តិការ ដែលមិនបានគ្រោងទុកមុន ឬ អាចប៉ាន់ស្មានថានឹងអាចកើតឡើងនោះ អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ ឬអ្នកផ្គត់ផ្គង់សេវាទឹកស្អាតរាយ ដោយគិតតាមករណីជាក់ស្តែងនីមួយៗ ត្រូវប្រញាប់ជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ដោយត្រូវបញ្ជាក់កាលបរិច្ឆេទ និងម៉ោងពេលចាប់ផ្តើមការផ្អាកប្រតិបត្តិការ ដែលមិនបានគ្រោងទុកមុននោះ ក៏ដូចជារយៈពេលប៉ាន់ស្មានដែលវាអាចអូសបន្លាយ។ រយៈពេលគិតចាប់ពីការផ្អាកប្រតិបត្តិការ ដែលមិនបានគ្រោងទុកមុនរហូតដល់ពេលដំណើរការប្រតិបត្តិការសេវាកម្មឡើងវិញនោះត្រូវសម្គាល់ហៅថា «រយៈពេលការផ្អាកប្រតិបត្តិការ ដែលមិនបានគ្រោងទុកមុន»។

១១.៣.២. ហេតុការណ៍បន្ទាន់ ៖ ក្នុងករណីមានហេតុការណ៍បន្ទាន់ អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំអាចកាត់បន្ថយកម្រិត ឬ បញ្ឈប់ការផ្គត់ផ្គង់ទឹកស្អាតជូនអ្នកផ្គត់ផ្គង់សេវាទឹកស្អាតរាយ។ បើអាចធ្វើទៅបាន អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំត្រូវជូនដំណឹងអ្នកផ្គត់ផ្គង់សេវាទឹកស្អាតរាយ ជាមុនសិន មុនពេលអនុវត្តសិទ្ធិរបស់ខ្លួនដូចចែងក្នុងប្រការ ១១.៣.២.នេះ (ហេតុការណ៍បន្ទាន់)។ អ្នកផ្គត់ផ្គង់សេវាទឹកស្អាតរាយ ត្រូវយល់ស្របតាមសំណើសមហេតុផលរបស់អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ ទាក់ទងនឹងការកាត់បន្ថយកម្រិត ឬបញ្ឈប់ការផ្គត់ផ្គត់ទឹកក្នុងហេតុការណ៍បន្ទាន់ដូច្នេះ។ ប្រសិនអ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំពិតជាអនុវត្តសិទ្ធិរបស់ខ្លួនដូចចែង ក្នុងផ្នែកនេះមែននោះ អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំត្រូវដាក់ចេញវិធានការចាំបាច់នានាដើម្បីដំណើរការផ្គត់ផ្គង់ទឹកស្អាតឡើងវិញឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។

# ១២. ការបង់ប្រាក់

## ១២.១.ថ្លៃតំណ

១២.១.១. ថ្លៃតំណ ៖ អ្នកផ្គត់ផ្គង់សេវាទឹកស្អាតរាយ ត្រូវបង់ថ្លៃតំណចំនួន [ចំនួនជាលេខ] (ចំនួនជាអក្សរ) រៀលជូន អ្នកផ្គត់ផ្គង់សេវា លក់ទឹកដុំ នៅ [កាលបរិច្ឆេទចាប់មានអានុភាពកិច្ចព្រមព្រៀងនេះ] («ថ្លៃតំណ») ដើម្បីអាចភ្ជាប់បណ្តាញទឹកស្អាតរបស់អ្នកផ្គត់ផ្គង់សេវាទឹកដុំបាន។

## ១២.២.ប្រាក់កក់

១២.២.១. ថ្លៃប្រាក់កក់ ៖ អ្នកផ្គត់ផ្គង់សេវាទឹកស្អាតរាយ ត្រូវបង់ប្រាក់កក់ចំនួន [ចំនួនជាលេខ] (ចំនួនជាអក្សរ) រៀលជូនអ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ នៅ [កាលបរិច្ឆេទចាប់មានអានុភាពកិច្ចព្រមព្រៀងនេះ] («ប្រាក់កក់»)។

១២.២.២. ការសងប្រាក់កក់ ៖ នៅពេលផុតចិរវេលាសុពលភាពនៃកិច្ចព្រមព្រៀងនេះ ឬពេលបញ្ចប់កិច្ចព្រៀងនេះមុនកាលកំណត់នោះ អ្នកផ្គត់ផ្គង់សេវាលក់ទឹកដុំ ត្រូវសងប្រាក់កក់ទៅឲ្យអ្នកផ្គត់ផ្គង់សេវាទឹកស្អាតរាយវិញ ដោយមិនគិតការប្រាក់អ្វីឡើយ ក្នុងអំឡុង១៥ថ្ងៃបន្ទាប់ពីអ្នកផ្គត់ផ្គង់សេវាទឹកស្អាតរាយបានទូទាត់វិក្កយបត្រជំពាក់ប្រាក់ និងថ្លៃប្រាក់បង់យឺតនានាដូចកំណត់ចំណុចទី

១២.៦. (ការបង់ប្រាក់យឺត)។ វិធីមួយទៀតនោះគឺ បើមានការស្នើសុំជាលាយល័ក្ខណ៍អក្សររបស់អ្នកផ្តល់សេវាទឹកស្អាតរាយ អ្នកផ្តល់សេវាលក់ទឹកដុំអាចផាត់សងប្រាក់ដែលអ្នកផ្តល់សេវាទឹកស្អាតរាយ ជំពាក់ខ្លួន ហើយទើបប្រគល់ប្រាក់នៅសល់ពីការផាត់សងនោះជូនអ្នកផ្តល់សេវាទឹកស្អាតរាយ តាមក្រោយតែម្តង។

## ១២.៣.ថ្លៃទិញទឹកដុំ

ក្នុងអំឡុងពិរវេលាសុពលភាពកិច្ចព្រមព្រៀងនេះ អ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវបង់ថ្លៃសេវាកម្មជូនអ្នកផ្តល់សេវាទឹកដុំ សម្រាប់ទឹកផ្គត់ផ្គង់ជូនខ្លួនជារៀងរាល់ខែគិតវិក្កយបត្រ។ ថ្លៃសេវាកម្មនឹងត្រូវគណនាដោយគុណថ្លៃលក់ទឹក នឹងបរិមាណទឹកផ្គត់ផ្គង់ដូចបង្ហាញតាមរូបមន្តខាងក្រោមនេះ ៖

(ក) ប្រសិនបរិមាណទឹកផ្គត់ផ្គង់ជាក់ស្តែងច្រើនជាងបរិមាណអប្បបរមាក្នុងមួយខែ រូបមន្តអនុវត្តគឺដូចតទៅ ៖

S = (T x AW)

(ខ) ប្រសិនបរិមាណទឹកផ្គត់ផ្គង់ជាក់ស្តែងតិចជាង ឬស្មើបរិមាណអប្បបរមារូបមន្តអនុវត្តគឺដូចតទៅ ៖

S = (T x MQ)

S = ថ្លៃទិញទឹកដុំ គិតជា រៀល

T = ថ្លៃលក់ទឹក (Tariff) គិតជា រៀលក្នុងមួយម៉ែត្រគូប

AW = បរិមាណទឹកផ្គត់ផ្គង់ជាក់ស្តែង (Actual Contracted Water Quantity) គិតជាម៉ែត្រគូប

MQ = បរិមាណអប្បបរមា (Minimum Quantity) គិតជាម៉ែត្រគូបក្នុងមួយខែ

## ១២.៤.វិក្កយបត្រ

ដោយមិនត្រូវយឺតជាង [ថ្ងៃធ្វើការទីប្រាំក្នុងខែនីមួយៗ] អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវផ្ញើវិក្កយបត្រជូនអ្នក ផ្តល់សេវាទឹកស្អាតរាយ ដោយវិក្កយបត្រនោះត្រូវបញ្ជាក់ពីការគណនាថ្លៃសេវាកម្ម និងចំនួនប្រាក់សរុបដែលអ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវទូទាត់ជូនអ្នកផ្តល់សេវាលក់ទឹកដុំ («**វិក្កយបត្រ**») សម្រាប់ប្រតិបត្តិការក្នុងខែមុន។

## ១២.៥.លក្ខខណ្ឌបង់ប្រាក់

១២.៥.១. <u>ប្រាក់ត្រូវបង់</u> ៖ អ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវទូទាត់ប្រាក់ជំពាក់ក្នុងវិក្កយបត្រនីមួយៗក្នុងអំឡុង [១៥ (ដប់ប្រាំ)] ថ្ងៃរាប់ចាប់ពីថ្ងៃខ្លួនទទួលបានវិក្កយបត្រនោះ។ ប្រសិនថ្ងៃកំណត់ចុងក្រោយសម្រាប់ការបង់ប្រាក់មិនចំថ្ងៃធ្វើការ ការបង់ប្រាក់ត្រូវធ្វើនៅថ្ងៃធ្វើការបន្ទាប់នោះ។

១២.៥.២. រូបិយវត្ថុ ៖ រាល់វិក្កយបត្រគឺគិតជាប្រាក់រៀលខ្មែរ ហើយរាល់ចំនួនប្រាក់ត្រូវបង់ក៏ត្រូវបង់ជាប្រាក់រៀលខ្មែរដែរ។

១២.៥.៣. ថ្លៃសេវាធនាគារ៖ រាល់ថ្លៃសេវាធនាគារគឺជាបន្ទុករបស់អ្នកផ្តល់សេវាទឹកស្អាតរាយ ។

**១២.៦.ពន្ធ**

ភាគីនីមួយៗមានកាតព្វកិច្ចបង់ពន្ធដែលតម្រូវលើខ្លួនស្របតាមការកំណត់របស់ច្បាប់កម្ពុជា។

**១២.៧.ការបង់ប្រាក់យឺត**

ប្រាក់ជំពាក់ណាក៏ដោយដែលមិនត្រូវបានទូទាត់ក្នុងអំឡុងពេលកំណត់ក្នុងប្រការ ១២.៥. (លក្ខខណ្ឌបង់ប្រាក់) ត្រូវជាប់ការប្រាក់ [បញ្ចូល]% ក្នុងមួយឆ្នាំ («អត្រាប្រាក់ពិន័យ») រាប់ចាប់ពីថ្ងៃអ្នកផ្តល់សេវាទឹកស្អាតរាយត្រូវបង់ប្រាក់នោះ តែមិនបានបង់រហូតដល់ថ្ងៃដែលអ្នកផ្តល់ សេវាទឹកស្អាតរាយ នោះបានបង់ប្រាក់។

**១២.៨.វិក្កយបត្រមានវិវាទ**

១២.៨.១. ការជូនដំណឹង និងការបង់ប្រាក់ ៖ ប្រសិនបើ អ្នកផ្តល់សេវាទឹកស្អាតរាយ ជំទាស់នឹងចំនួនប្រាក់ត្រូវបងនៅក្នុងវិក្កយបត្រ ឬវិធីគណនាប្រាក់ត្រូវបង់ណាមួយក្នុងវិក្កយបត្រនោះ អ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវ ៖ (i) ផ្ញើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជូនអ្នកផ្តល់សេវាលក់ទឹកដុំ ដើម្បីប្រាប់អ្នកផ្តល់សេវាលក់ទឹកដុំ ពីបញ្ហានេះ ក៏ដូចជាមូលដ្ឋានដែលខ្លួនជំទាស់ និង (ii) បង់ចំណែកនៃប្រាក់ជំពាក់ក្នុងវិក្កយបត្រដែលខ្លួនមិនជំទាស់កុំឲ្យយឺតជាងថ្ងៃត្រូវបង់វា។

១២.៨.២. ការដោះស្រាយវិវាទ ៖ គូភាគីត្រូវព្យាយាមដោះស្រាយវិវាទទាក់ទងនឹងការចេញវិក្កយបត្រក្នុងអំឡុង[សាមសិប (៣០)] ថ្ងៃរាប់ចាប់ពីពេលដែលអ្នកផ្តល់សេវាលក់ទឹកដុំ បានទទួលលិខិតជូនដំណឹងរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ។ ប្រសិនវិវាទត្រូវបានដោះស្រាយដោយអ្នកផ្តល់សេវាទឹកដុំមិនត្រូវរកឃើញកំហុសនោះ ចំនួនប្រាក់ជំពាក់មានវិវាទនោះត្រូវសន្មតថាជាប់ការប្រាក់ក្នុងរូបភាពជាអត្រាប្រាក់ពិន័យចាប់តាំងពីថ្ងៃវាត្រូវបង់ដំបូងរហូតដល់ថ្ងៃដែលវាត្រូវបានបង់ជូនអ្នកផ្តល់សេវាលក់ទឹកដុំ ។

**១២.៩. ការកែតម្រូវវិក្កយបត្រ**

១២.៩.១.កាលបរិច្ឆេទកែតម្រូវ ៖ ការកែតម្រូវត្រូវគណនារកកាលបរិច្ឆេទដែលគូភាគី ឯកភាពគ្នាថាជាកាលបរិច្ឆេទចាប់ផ្តើមកើតមានបញ្ហាទាក់ទងនឹងនាឡិកាទឹក ឬឧបករណ៍វាស់ផ្សេងៗ។ ដំណោះស្រាយនេះត្រូវយកមកអនុវត្ត ក្នុងករណីដែលអាចកំណត់កាលបរិច្ឆេទ បាន ដូចជាមានការកត់ត្រាលើប្រតិបត្តិការជាប្រចាំ ឬការប្រែប្រួលចរន្តហូរទឹកគួរឲ្យកត់សម្គាល់ណាមួ

យ។ ប្រសិនបើ គូភាគីមិនអាចព្រមព្រៀងគ្នាលើការកំណត់កាលបរិច្ឆេទណាមួយ ដាកាលបរិច្ឆេទចាប់ផ្តើមកើតមានបញ្ហាទាក់ទងនឹងនាឡិកាទឹក ឬឧបករណ៍វាស់ផ្សេងៗទេនោះ កាលបរិច្ឆេទសម្រាប់ការកែតម្រូវវិក្កយបត្រគឺ [កាលបរិច្ឆេទនៃការធ្វើសនវកម្មលើកចុងក្រោយបង្អស់/កាលបរិច្ឆេទនៃការជូនដំណឹងជាលាយលក្ខណ៍អក្សរពីការធ្វើសវនកម្ម]។

## ១៣. ការបង់សំណង

### ១៣.១.ការបង់សំណងរបស់អ្នកផ្តល់សេវាលក់ទឹកដុំ

អ្នកផ្តល់សេវាលក់ទឹកដុំ ត្រូវបង់សំណង ការពារ និង បញ្ចៀសមិនឲ្យមានការប៉ះពាល់លើអ្នកផ្តល់សេវាទឹកស្អាតរាយ ពីរាល់ការទាមទាររបស់ ភាគីទីបី ប្រឆាំងនឹងអ្នកផ្តល់សេវាទឹកស្អាតរាយ ដែលកើតចេញពី ៖

(ក) ការបាត់បង់ ឬការខូចខាតលើទ្រព្យសម្បត្តិ ឬមរណភាព ឬរបួសរបស់បុគ្គលដែលបណ្តាលមកពីការធ្វេសប្រហែស ឬអសកម្មភាពរបស់អ្នកផ្តល់សេវាទឹកដុំ ក្នុងពេលអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀងនេះ ឬ

(ខ) ការខកខានបំពេញកាតព្វកិច្ចណាមួយរបស់អ្នកផ្តល់សេវាលក់ទឹកដុំ តាមកិច្ចព្រមព្រៀងនេះ។

អ្នកផ្តល់សេវាលក់ទឹកដុំមិនមានកាតព្វកិច្ចបង់សំណងជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ដែលបានកំណត់ដោយ កថាខណ្ឌ (ក) និង (ខ) ខាងលើនោះឡើយ ប្រសិនបើស្ថានភាពនោះកើតចេញពីការធ្វេសប្រហែសកំហុស ឬការរំលោភបំពានកិច្ចព្រមព្រៀងនេះរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ ឬដោយសារតែវាជាលទ្ធផលផ្ទាល់នៃការណ៍ដែលអ្នកផ្តល់សេវាលក់ទឹកដុំ ធ្វើតាមការណែនាំរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ តែប៉ុណ្ណោះ។

### ១៣.២.ការបង់សំណងរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ

អ្នកផ្តល់សេវាទឹកស្អាតរាយ ត្រូវបង់សំណង ការពារ និងបញ្ចៀសមិនឲ្យមានការប៉ះពាល់លើអ្នកផ្តល់សេវាលក់ទឹកដុំ ក៏ដូចជាភាគីខាងអ្នកផ្តល់សេវាលក់ទឹកដុំ ពីរាល់ការទាមទាររបស់ ភាគីទីបី ប្រឆាំងនឹងអ្នកផ្តល់សេវាលក់ទឹកដុំ ឬភាគីខាងអ្នកផ្តល់សេវាលក់ទឹកដុំ ដែលកើតចេញពី ៖

(ក) ការបាត់បង់ ឬខូចខាតលើទ្រព្យសម្បត្តិ ឬមរណភាព ឬរបួសរបស់បុគ្គលដែ បណ្តាល មកពីការធ្វេសប្រហែស ឬអសកម្មភាពភាពរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ ឬ ភាគីខាងអ្នកផ្តល់សេវាទឹកស្អាតរាយ ក្នុងពេលអនុវត្តកាតព្វកិច្ចតាមកិច្ចព្រមព្រៀងនេះ ឬ

(ខ) ការខកខានបំពេញកាតព្វកិច្ចណាមួយរបស់អ្នកផ្តល់សេវាទឹកស្អាតរាយតាមកិច្ចព្រមព្រៀងនេះ។

អ្នកផ្តល់សេវាទឹកស្អាតរាយ មិនមានកាតព្វកិច្ចបង់សំណងជូនអ្នកផ្តល់សេវាលក់ទឹកដុំ ឡើយដែលបានកំណត់ដោយកថាខណ្ឌ (ក) និង (ខ) ខាងលើ ប្រសិនបើស្ថានភាពនោះកើតចេញពីការធ្វេសប្រហែសកំហុស ឬការរំលោភបំពានកិច្ចព្រមព្រៀងនេះរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ ឬភាគីខាងអ្នកផ្តល់សេវាលក់ទឹកដុំ

ឬ ដោយសារតែវាជាលទ្ធផលផ្ទាល់នៃការណ៍ដែលអ្នកផ្តល់សេវាទឹកស្អាតរាយ ធ្វើតាមការណែនាំរបស់អ្នកផ្តល់សេវាលក់ទឹកដុំតែប៉ុណ្ណោះ។

### ១៣.៣.វិធីបង់សំណង

១៣.៣.១. ការជូនដំណឹងពីការទាមទារ ៖ ភាគីនីមួយៗត្រូវជូនដំណឹងភាគីមួយទៀតជាលាយល័ក្ខណ៍អក្សរពីស្ថានភាពដែលនាំឲ្យកើត ឬ អាចនាំឲ្យកើតការទាមទារតាម ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ ដែលជាវិបាកអាចនាំឲ្យមានការមានស្នើបង់សំណងដូចកំណត់ក្នុងប្រការ ១៣ (ការបង់សំណង) នេះ ហើយដោយការជូនដំណឹងនេះទៀតសោតត្រូវធ្វើភ្លាមក្រោយពេលខ្លួនដឹងពីស្ថានភាពការទាមទារនោះ។

១៣.៣.២. ការតតាំងនឹងការទាមទារ ៖ភាគីជាប់បន្ទុកបង់សំណងអាចសម្រេចចិត្តចេញចំណាយផ្ទាល់ខ្លួនដើម្បីធ្វើការ តតាំងនឹងការទាមទារដែលទាក់ទងនឹងស្ថានភាពដែលតម្រូវ ឬអាចតម្រូវឲ្យខ្លួនបង់សំណងជូនភាគីទទួលសំណងតាមកិច្ចព្រមព្រៀងនេះ ហើយដែលក្នុងនីតិវិធីការទាមទារនោះខ្លួន ឬភាគីទទួលសំណងជាប់ឈ្មោះជាគូក្តី។ ប្រសិនបើភាគីទទួលសំណងក៏ជាប់ឈ្មោះជាគូក្តីក្នុងដំណើរការនីតិវិធីរឿងក្តីទាមទារដែរនោះ ភាគីទទួលសំណងមានសិទ្ធិពឹងពាក់មេធាវីផ្ទាល់ខ្លួនដោយចេញចំណាយផ្ទាល់ខ្លួនឯងបាន។ លើកលែងតែករណីការទាមទារនោះបង្កផលប៉ះពាល់អវិជ្ជមានលើប្រយោជន៍របស់គូភាគីនោះ ភាគីជាប់បន្ទុកបង់សំណងត្រូវ (i) ផ្តល់ព័ត៌មានទាក់ទងនឹងនីតិវិធីតតាំងក្តីរបស់ខ្លួនជូនភាគីទទួលសំណង និងមេធាវីរបស់ភាគីនេះជាប្រចាំ (ii) ផ្តល់ឱកាសគ្រប់គ្រាន់ជូនភាគីទទួលសំណង ក៏ដូចជាមេធាវីរបស់ភាគីនេះដើម្បីពិនិត្យមើល និងផ្តល់អនុសាសន៍លើឯកសារសំណុំរឿង និងពាក្យស្នើសុំនានាទាក់ទងនឹងការទាមទារមុនខ្លួនដាក់ឯកសារ និងពាក្យស្នើសុំទាំងនោះ និង (iii) ទទួលយកយោបល់របស់ភាគីទទួលសំណង ឬមេធាវីរបស់ភាគីនេះមកពិចារណាដោយសុទ្ធចិត្ត ឬអនុញ្ញាតឲ្យភាគីទទួលសំណង និងមេធាវីរបស់ភាគីនេះដាក់ឯកសារ ឬចូលរួមក្នុងដំណាក់កាលមួយចំនួននៃជំនួប ឬនីតិវិធីរឿងក្តីទាមទារនោះ។

១៣.៣.៣. ការបង់សំណងតាមការទាមទារ ៖ ភាគីជាប់បន្ទុកបង់សំណងត្រូវបង់សំណងជូនភាគីទទួលសំណងក្នុងអំឡុងសាមសិប (៣០) ថ្ងៃបន្ទាប់ពីភាគីទទួលសំណងជូនដំណឹងខ្លួនពីការបានបង់ប្រាក់តាមការទាមទារហើយ។

## ១៤. ប្រធានសក្តិ

### ១៤.១.ហេតុការណ៍ប្រធានសក្តិ

ប្រសិនភាគីមិនអាចបំពេញកាតព្វកិច្ចណាមួយរបស់ខ្លួនដូចកំណត់ក្នុងកិច្ចព្រមព្រៀងនេះទាំងស្រុង ឬត្រឹមផ្នែកណាមួយនៃកាតព្វកិច្ចនោះដោយសារហេតុការណ៍ប្រធានសក្តិនោះ ភាគីនោះត្រូវរួសរាន់ជូនដំណឹងភាគីមួយទៀតពីបញ្ហានេះភ្លាម។ ការជូនដំណឹងនេះត្រូវ ៖

(ក) បញ្ជាក់ពីកាតព្វកិច្ចដែលខ្លួនមិនអាចបំពេញបាន

(ខ) រៀបរាប់ពីហេតុការណ៍ប្រធានសក្តិឲ្យបានគ្រប់ជ្រុងជ្រោយ

(គ) ប៉ាន់ស្មានពីអំឡុងពេលដែលហេតុការណ៍ប្រធានសក្តិកើតឡើង

(ឃ) បញ្ជាក់ពីមធ្យោបាយដែលខ្លួនគ្រោងនឹងប្រើប្រាស់ដើម្បីទប់ទល់នឹងហេតុការណ៍ប្រធានសក្តិ

ក្រៅពីនេះ ភាគីដែលរងផលប៉ះពាល់ពីហេតុការណ៍ប្រធានសក្តិត្រូវផ្តល់ព័ត៌មានជូនភាគីមួយទៀតពីចំណុចទាំងអម្បាលម៉ានខាងលើនេះជាប្រចាំ ឬភ្លាមៗពេលមានការស្នើសុំរបស់ភាគីមួយទៀត ។

### ១៤.២.ការព្យួរកាតព្វកិច្ច

ក្រោយមានការជូនដំណឹងនេះ កាតព្វកិច្ចដែលមិនអាចបំពេញបានដោយសាររងផលប៉ះពាល់ពីហេតុការណ៍ប្រធានសក្តិនោះត្រូវព្យួរសិនដរាបណាហេតុការណ៍ប្រធានសក្តិនៅតែបន្តកើតមាន។

### ១៤.៣.ដំណោះស្រាយពេលកើតមានប្រធានសក្តិ

ភាគីដែលរងផលប៉ះពាល់ពីហេតុការណ៍ប្រធានសក្តិត្រូវប្រើប្រាស់គ្រប់មធ្យោបាយដែលចាំបាច់ដើម្បីដោះស្រាយបញ្ហាបង្កឡើងដោយហេតុការណ៍ប្រធានសក្តិ ហើយត្រូវចាប់អនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើងវិញឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។

### ១៤.៤.ការកាត់បន្ថយផលប៉ះពាល់

ភាគីដែលរងផលប៉ះពាល់ពីហេតុការណ៍ប្រធានសក្តិត្រូវប្រើប្រាស់គ្រប់មធ្យោបាយដែលចាំបាច់ដើម្បីកាត់បន្ថយការខាតបង់របស់ភាគីមួយទៀតដែលបណ្តាលមកពីការខកខានរបស់ខ្លួនក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចព្រមព្រៀងនេះ។

## ១៥. ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀង

### ១៥.១.ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្តល់សេវាលក់ទឹកដុំ

ករណីដូចខាងក្រោមនេះត្រូវចាត់ទុកជាករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្តល់សេវាលក់ទឹកដុំ ៖

(ក) អ្នកផ្តល់សេវាលក់ទឹកដុំ ខកខានបំពេញកាតព្វកិច្ចណាមួយរបស់ខ្លួនដែលកំណត់ក្នុងកិច្ចព្រមព្រៀងនេះ ហើយដោយការខកខាននោះបណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរ និងអវិជ្ជមានលើការផ្តល់សេវាកម្មរបស់ខ្លួន។

(ខ) អ្នកផ្តល់សេវាលក់ទឹកដុំដាក់ពាក្យសុំប្រកាសថាខ្លួនអសាធនីយ ឬត្រូវបានតុលាការប្រកាសថាអសាធនីយ ឬធ្វើអនុប្បទានអត្ថប្រយោជន៍ខ្លួនជូនម្ចាស់បំណុល ឬទទួលស្គាល់ជា លាយល័ក្ខណ៍អក្សរថា ខ្លួនមិនមាន

លទ្ធភាពដោះស្រាយបំណុលទូទៅរបស់ខ្លួន ឬប្រសិនមានពាក្យសុំណាមួយឲ្យប្រកាសថា អ្នកផ្គល់សេវាលក់ទឹកដុំ ក្ស័យធន ឬត្រូវរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ខ្លួនឡើងវិញដោយអនុលោមច្បាប់កម្ពុជាត្រូវបានដាក់ជូនតុលាការ ហើយទីបំផុតអ្នកផ្គល់សេវាលក់ទឹកដុំត្រូវបានតុលាការប្រកាសថា ក្ស័យធន ហើយដោយការប្រកាសរបស់តុលាការនោះមិនត្រូវបានលុបចោល ឬលើកចោលក្នុងអំឡុងហុកសិប (៦០) ថ្ងៃក្រោយមានការចេញដីកាប្រកាសនោះ។

### ១៥.២.ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្គល់សេវាទឹកស្អាតរាយ

ករណីដូចខាងក្រោមនេះត្រូវចាត់ទុកជាករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្គល់សេវាទឹកស្អាតរាយ ៖

(ក) អ្នកផ្គល់សេវាទឹកស្អាតរាយ បន្តខកខានបំពេញកាតព្វកិច្ចសំខាន់ណាមួយរបស់ខ្លួនដែលកំណត់ក្នុងកិច្ចព្រមព្រៀងនេះ ហើយដោយការខកខាននោះធ្វើឲ្យក្រុមអ្នកផ្គល់សេវាលក់ទឹកដុំ មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនយោងតាមកិច្ចព្រមព្រៀងនេះក្នុងអំឡុងហុកសិប (៦០) ថ្ងៃជាប់គ្នា។

(ខ) អ្នកផ្គល់សេវាលក់ទឹកស្អាតរាយ ខកខានបង់ប្រាក់ជំពាក់ណាមួយ (មិនសំដៅប្រាក់ជំពាក់មានវិវាទគ្នាទេ) តាមការអនុវត្តកិច្ចព្រមព្រៀងនេះ ហើយដោយការខកខាននោះមិនត្រូវបានដោះស្រាយក្នុងអំឡុងហុកសិប (៦០) ថ្ងៃរាប់ចាប់ពីពេលអ្នកផ្គល់សេវាទឹកស្អាតរាយ ទទួលការជូនដំណឹងជាលាយល័ក្ខណ៍អក្សររបស់អ្នកផ្គល់សេវាលក់ទឹកដុំទាក់ទងនឹងប្រាក់ជំពាក់នោះ។

(គ) អ្នកផ្គល់សេវាទឹកស្អាតរាយ ដាក់ពាក្យសុំប្រកាសថាខ្លួនអសាធនីយ ឬត្រូវបានតុលាការប្រកាសថាអសាធនីយ ឬធ្វើអនុប្បទានអត្ថប្រយោជន៍ខ្លួនជូនម្ចាស់បំណុល ឬទទួលស្គាល់ជាលាយល័ក្ខណ៍អក្សរថា ខ្លួនមិនមានលទ្ធភាពដោះស្រាយបំណុលទូទៅរបស់ខ្លួន ឬប្រសិនមានពាក្យសុំណាមួយឲ្យប្រកាសថា អ្នកផ្គល់សេវាទឹកស្អាតរាយ ក្ស័យធន ឬត្រូវរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងរបស់ខ្លួនឡើងវិញដោយអនុលោមច្បាប់កម្ពុជាត្រូវបានដាក់ជូនតុលាការ ហើយទីបំផុតអ្នកផ្គល់សេវាទឹកស្អាតរាយត្រូវបានតុលាការប្រកាសថា ក្ស័យធន ហើយដោយការប្រកាសរបស់តុលាការនោះមិនត្រូវបានលុបចោល ឬលើកចោលក្នុងអំឡុងហុកសិប (៦០) ថ្ងៃក្រោយមានការចេញដីកាប្រកាសនោះ។

## ១៦. ការបញ្ចប់កិច្ចព្រមព្រៀង

### ១៦.១.ការបញ្ចប់កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះត្រូវបញ្ចប់ ប្រសិន ៖

(ក) គូភាគីព្រមព្រៀងគ្នាជាលាយល័ក្ខណ៍អក្សរ ឬ

(ខ) ភាគីណាមួយបង្កករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀង

### ១៦.២.វិធីបញ្ចប់កិច្ចព្រមព្រៀង

បន្ទាប់ពីកើតមានករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀង វិធីសាស្ត្រដោះស្រាយដូចបង្ហាញខាងក្រោមនេះត្រូវយកមកអនុវត្ត ៖

(ក) ភាគីដែលមិនបានបង្កកំហុសត្រូវជូនដំណឹង («ការជូនដំណឹងពីការមិនអនុវត្តកិច្ចព្រមព្រៀង») ភាគីបង្កកំហុស ដោយរៀបរាប់លម្អិតពីករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀង និងចង្អុលបង្ហាញកាលបរិច្ឆេទនៃការកើតករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងនោះ។

(ខ) ភាគីបង្កកំហុសមានពេលសាមសិប (៣០) ថ្ងៃរាប់ចាប់ពីថ្ងៃទទួលបានការជូនដំណឹងពីការមិនអនុវត្តកិច្ចព្រមព្រៀងដើម្បីកែតម្រូវករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងនោះ។

(គ) ប្រសិនភាគីបង្កកំហុសត្រូវការពេលវេលាច្រើនជាងពេលវេលាខាងលើនេះដើម្បីកែតម្រូវកំហុសរបស់ខ្លួន ភាគីបង្កកំហុសត្រូវប្រគល់ជូនភាគីដែលមិនបង្កកំហុសនូវផែនការមួយ («ផែនការកែតម្រូវ») ក្នុងអំឡុងដប់ (១០) ថ្ងៃរាប់ចាប់ពីថ្ងៃខ្លួនទទួលបានការជូនដំណឹងពីការមិនអនុវត្តកិច្ចព្រមព្រៀង (ឬក្នុងអំឡុងពេលមួយវែងជាងនេះឲ្យតែមានការយល់ព្រមរបស់ភាគីដែលមិនបង្កកំហុស) ដោយត្រូវបញ្ជាក់ពីវិធានការកែតម្រូវដែលភាគីបង្កកំហុសគ្រោងដាក់ចេញ និងចំនួនថ្ងៃត្រូវការចាំបាច់ដើម្បីកែតម្រូវករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងនោះ។ ផែនការកែតម្រូវត្រូវឆ្លងកាត់ការយល់ព្រមជា លាយល័ក្ខណ៍ជាមុនរបស់ភាគីមិនបង្កកំហុស ហើយភាគីនេះត្រូវចៀសវាងបដិសេធវាដោយគ្មានមូលហេតុត្រឹមត្រូវ។

(ឃ) ប្រសិនករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងនោះមិនត្រូវបានកែតម្រូវក្នុងអំឡុង [សាមសិប (៣០)] ថ្ងៃ (ឬក្នុងអំឡុងពេលមួយវែងជាងនេះឲ្យតែមានការយល់ព្រមរបស់ភាគីដែលមិនបង្កកំហុស) ភាគីមិនបង្កកំហុសនឹងមានសិទ្ធិភ្លាមក្នុងការបញ្ចប់កិច្ចព្រមព្រៀងនេះ ដោយខ្លួនត្រូវជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀង («ការជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀង») ទៅភាគីបង្កកំហុស។ ការបញ្ចប់កិច្ចព្រមព្រៀងនឹងចាប់មានប្រសិទ្ធភាពនៅកាលបរិច្ឆេទដែលភាគីដែលមិនបង្កកំហុសបានកំណត់ក្នុងលិខិតជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀងនោះ ឲ្យតែយ៉ាងណាកុំតិចជាង [សាមសិប (៣០)] ថ្ងៃរាប់ចាប់ពីកាលបរិច្ឆេទដែលភាគីបង្កកំហុសបានទទួលលិខិតជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀងនោះ។

## ១៧. ការជូនដំណឹង

### ១៧.១.ការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ

រាល់ការជូនដំណឹង ការស្នើទាមទារ និងការប្រាស្រ័យផ្សេងទៀតទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនេះត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ហើយលើកលែងតែមានការកំណត់ដោយឡែក ត្រូវបញ្ជូនដោយផ្ទាល់ដៃ តាមអ៊ីម៉ែល ឬតាមសេវាបញ្ជូនសារចុះបញ្ជីត្រឹមត្រូវ។ លិខិតជូនដំណឹង លិខិតស្នើទាមទារ និងលិខិតប្រាស្រ័យផ្សេងទៀតទាំងអស់នេះត្រូវសន្មតថាបានទទួលនៅថ្ងៃបញ្ជូនវាតែម្តង។

### ១៧.២.ព័ត៌មានសម្រាប់ប្រាស្រ័យទាក់ទង-ជូនដំណឹង

លិខិតជូនដំណឹងនីមួយៗដែលផ្ញើទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនេះត្រូវបញ្ជូននៅទីកន្លែងដូចខាងក្រោម ៖

ប្រសិនផ្ញើជូនអ្នកផ្តល់សេវាលក់ទឹកដុំ

ជូនចំពោះ ៖

អាសយដ្ឋាន ៖

អ៊ីម៉េល ៖

ទូរស័ព្ទ ៖

ប្រសិនផ្ញើជូនអ្នកផ្តល់សេវាទឹកស្អាតរាយ

ជូនចំពោះ ៖

អាសយដ្ឋាន ៖

ទូរសារ ៖

អ៊ីម៉េល ៖

ទូរស័ព្ទ ៖

### ១៧.៣.ការផ្លាស់ប្តូរព័ត៌មានសម្រាប់ប្រាស្រ័យទាក់ទង-ជូនដំណឹង

ភាគីនីមួយៗអាចផ្លាស់ប្តូរព័ត៌មានសម្រាប់ប្រាស្រ័យទាក់ទង-ជូនដំណឹងរបស់ខ្លួនបានដោយត្រូវជូនដំណឹងភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ។

### ១៧.៤.ការជូនដំណឹងជាភាសាខ្មែរ

លិខិតជូនដំណឹងនីមួយៗដែលផ្ញើទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀងនេះត្រូវតែធ្វើជាភាសាខ្មែរ ។

## ១៨. ច្បាប់គ្រប់គ្រង និងការដោះស្រាយវិវាទ

### ១៨.១.ច្បាប់គ្រប់គ្រង

កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់របស់ប្រទេសកម្ពុជា។

### ១៨.២.ការដោះស្រាយវិវាទ

១៨.២.១. ការពិភាក្សាទ្វេភាគី ៖ ស្របតាមស្មារតី និងបំណងនៃកិច្ចព្រមព្រៀងនេះ គូភាគីត្រូវព្យាយាមដោះស្រាយរាល់វិវាទដែលកើតឡើងទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ឬពាក់ព័ន្ធនឹងការរំលោភបំពានកិច្ចព្រមព្រៀងនេះដោយសន្តិវិធី និងក្តីយោគយល់គ្នាតាមរយៈការពិភាក្សាទ្វេភាគី។

១៨.២.២. ការសម្រុះសម្រួល ៖ ប្រសិនគូភាគីមិនអាចដោះស្រាយវិវាទរបស់ខ្លួនបានតាមរយៈការពិភាក្សាទ្វេភាគីក្នុងអំឡុង៣០ថ្ងៃ ភាគីណាមួយក៏បានអាចបញ្ជូនវិវាទនោះទៅកាន់ អគ្គនាយកដ្ឋានទឹក

ស្អាត នៃ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវនុវត្តន៍ (MISTI)ឲ្យជួយដោះស្រាយ។

១៨.២.៣. តុលាការកម្ពុជា ៖ ក្នុងករណីគូភាគីនៅតែមិនអាចដោះស្រាយវិវាទរបស់ខ្លួនតាម រយៈការសម្រុះសម្រួលរបស់អគ្គនាយកដ្ឋានទឹកស្អាត ឬអគ្គនាយកដ្ឋានទឹកស្អាតបដិសេធសម្រុះសម្រួលវិវាទរបស់ខ្លួននោះ ភាគីណាមួយក៏បានអាច បញ្ជូនវិវាទនោះប្តឹងទៅកាន់តុលាការកម្ពុជាឲ្យជួយសម្រេចសេចក្តី។

## ១៩. ចំណុចផ្សេងទៀត

### ១៩.១.ភាពសម្ងាត់

១៩.១.១. ព័ត៌មានសម្ងាត់ ៖ គ្មានភាគីណាមួយអាចបង្ហាញព័តមានសម្ងាត់របស់ភាគីមួយទៀតដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនរបស់ភាគីនោះឡើយ តែភាគីមួយអាចបង្ហាញព័តមានសម្ងាត់របស់ភាគីមួយទៀតបាន ៖

(ក) ជូនបុគ្គលិក អ្នកម៉ៅការគម្រោង ឬទីប្រឹក្សារបស់ខ្លួនដែលចាំបាច់ត្រូវដឹងព័ត៌មាននោះដើម្បីអាចជួយឲ្យភាគីនោះក្នុងការអនុវត្តសិទ្ធិ ឬបំពេញកាតព្វកិច្ចរបស់ខ្លួនដូចកំណត់ក្នុងកិច្ចព្រមព្រៀងនេះ ឬ

(ខ) ប្រសិនការបង្ហាញព័ត៌មាននោះគឺធ្វើឡើងតាមការតម្រូវរបស់ច្បាប់កម្ពុជា បញ្ជារបស់តុលាការ ឬ MISTI ឬ

(គ) ប្រសិនវាជាការតម្រូវដើម្បីខ្លួនទទួលបានហិរញ្ញប្បទាន ឬ

(ឃ) ប្រសិនវាជាការតម្រូវរបស់ផ្សារមូលបត្រ។

១៩.១.២. ការអនុញ្ញាតឲ្យបង្ហាញព័ត៌មានជូននិយោជិត អ្នកម៉ៅការគម្រោង ឬទីប្រឹក្សា ៖ ភាគីអាចត្រឹមតែបង្ហាញព័តមានសម្ងាត់ជូនបុគ្គលិក អ្នកម៉ៅការគម្រោង ឬទីប្រឹក្សារបស់ខ្លួនដូចកំណត់ក្នុងប្រការ ១៩.១.១.(ក) (ព័ត៌មានសម្ងាត់) ប្រសិនខ្លួនកំណត់ឲ្យបុគ្គលទាំងនោះគោរពកាតព្វកិច្ចមិនបង្ហាញព័ត៌មាននេះឲ្យបុគ្គលដទៃទៀតដឹង។

១៩.១.៣. ការបង្ហាញព័ត៌មានក្នុងស្ថានភាពផ្សេងទៀត ៖ ភាគីណាដែលបង្ហាញព័ត៌មានក្នុងស្ថានភាពកំណត់ក្នុងប្រការ ១៩.១.១.(ខ) (គ) និង (ឃ) (ព័ត៌មានសម្ងាត់) ត្រូវជូនដំណឹងភាគីម្ខាងទៀតជាមុនពីការតម្រូវ និងលក្ខខណ្ឌនានានៃការបង្ហាញព័ត៌មាននោះ និងត្រូវចាត់ចែងយ៉ាងណាឲ្យការបង្ហាញព័ត៌មានរបស់ភាគីម្ខាងទៀតនោះភ្ជាប់លក្ខខណ្ឌដែលធានាភាពសម្ងាត់បំផុត។

### ១៩.២. ភាពអាចផ្តាច់ពីគ្នានៃបញ្ញត្តិកិច្ចព្រមព្រៀង

អសុពលភាព អនីត្យានុកូលភាព ឬការមិនអាចអនុវត្តបាននៃបញ្ញត្តិណាមួយ ឬណាខ្លះនៃកិច្ចព្រមព្រៀងនេះនឹងមិនប៉ះពាល់ដល់ការបន្តអនុវត្តប្បញ្ញត្តិដទៃទៀតនៃកិច្ចព្រមព្រៀងនេះឡើយ។

### ១៩.៣. វិសោធនកម្ម

វិសោធនកម្មកិច្ចព្រមព្រៀងនេះ ឬឧបសម្ព័ន្ធរបស់វានឹងមិនមានសុពលភាព និងអានុភាព អនុវត្តចំពោះភាគីណាមួយឡើយបើវាមិនបានធ្វើឡើងជាលាយល័ក្ខណ៍អក្សរ និងមិនមាន ហត្ថលេខារបស់គូភាគី។

## ១៩.៤. ការបោះបង់សិទ្ធិ

ការណ៍ដែលភាគីណាមួយនៅពេលណាមួយក៏ដោយ ឬក្នុងអំឡុងពេលណាមួយក៏ដោយ មិនបានទាមទារឲ្យអនុវត្តប្បញ្ញត្តិ ឬលក្ខខណ្ឌណាមួយ ឬណាខ្លះក៏ដោយនៃកិច្ចព្រមព្រៀងនេះមិនមានន័យថា ភាគីនោះបោះបង់ចោលសិទ្ធិក្នុងការទាមទារឲ្យអនុវត្តប្បញ្ញត្តិ និងលក្ខខណ្ឌទាំងអស់នៃកិច្ចព្រមព្រៀងនេះនៅពេលក្រោយឡើយ។

## ១៩.៥. អនុប្បទាន

គ្មានភាគីណាមួយអាចធ្វើអនុប្បទាន ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចរបស់ខ្លួនដូចកំណត់ក្នុងកិច្ចព្រមព្រៀងនេះដោយមិនមានការយល់ព្រមជាលាយល័ក្ខណ៍អក្សរជាមុនរបស់ភាគីមួយទៀតឡើយ តែភាគីនេះក៏ត្រូវចៀសវាងជំទាស់ដោយគ្មានមូលហេតុត្រឹមត្រូវដែរ។ ទោះបីមានការកំណត់ដូច្នេះក្តី ភាគីនីមួយៗអាចធ្វើអនុប្បទានសិទ្ធិរបស់ខ្លួនជូនស្ថាប័ន-បុគ្គលផ្តល់ប្រាក់កម្ចីបានក្នុងរូបភាពជាលក្ខខណ្ឌដើម្បីខ្លួនទទួលបានហិរញ្ញប្បទាន។

## ១៩.៦. ការស្នងបន្តកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះនឹងមានអានុភាពអនុវត្តលើបណ្តាប្រតិសិទ្ធិ និងអនុប្បទានិកស្របច្បាប់របស់ភាគីនីមួយៗ រួមទាំងតតិយភាគីដែលធ្វើលទ្ធកម្មលើភាគីនោះ និង/ឬអាជីវកម្មរបស់ភាគីនោះផងដែរ។

## ១៩.៧. កិច្ចព្រមព្រៀងទាំងមូល

កិច្ចព្រមព្រៀងនេះ និងឧបសម្ព័ន្ធនានារបស់វាតំណាងឲ្យកិច្ចព្រមព្រៀងទាំងមូលរបស់គូភាគីលើកម្មវត្ថុដូចចែងកំណត់ក្នុងកិច្ចព្រមព្រៀងនេះ។ រាល់ការយល់ព្រម កិច្ចព្រមព្រៀង ការតំណាង ឬការធានាអះអាងផ្សេងទៀតពីមុនមកទាក់ទងនឹងកម្មវត្ថុដូចគ្នានេះត្រូវជំនួសដោយកិច្ចព្រមព្រៀងនេះ ហើយនឹងមិនមានអនុវត្តតទៀតឡើយ។

**[ចុះហត្ថលេខានៅទំព័របន្ទាប់]**

ភាគីនីមួយៗបានឯកភាពឲ្យអ្នកតំណាងស្របច្បាប់របស់ខ្លួនរៀងខ្លួនចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះនៅកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងនេះពិតប្រាកដមែន។

| សម្រាប់ និងក្នុងនាម<br>**អ្នកផ្តល់សេវាលក់ទឹកដុំ** | សម្រាប់ និងក្នុងនាម<br>**អ្នកផ្តល់សេវាទឹកស្អាតរាយ** |
|---|---|
| ឈ្មោះ ៖ | ឈ្មោះ ៖ |
| តួនាទី ៖ | តួនាទី ៖ |
| កាលបរិច្ឆេទ ៖ | កាលបរិច្ឆេទ ៖ |

## ឧបសម្ព័ន្ធទី១ - និយមន័យ

«**បរិមាណទឹកផ្គត់ផ្គង់ជាក់ស្តែង**» មានន័យថាបរិមាណទឹកជាក់ស្តែងគិតជាម៉ែត្រគូបដែលផ្គត់ផ្គង់ដោយអ្នកផ្តល់សេវាទឹកដុំជូនអ្នកផ្តល់សេវាទឹកស្អាតរាយនៅចំណុចប្រគល់។

«**នាឡិកាទឹក**» មានន័យថានាឡិកាដែលបំពាក់នៅចំណុចប្រគល់សម្រាប់វាស់បរិមាណទឹកដែលប្រគល់ជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ។

«**ខែគិតវិក្កយបត្រ**» មានន័យថា (i) អំឡុងពេលរាប់ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការរហូតដល់ថ្ងៃចុងក្រោយនៃខែនៃកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការនោះ, (ii) អំឡុងពេលមួយខែនីមួយៗរាប់ចាប់តពីនោះ តែមិនរាប់បញ្ចូលខែនៃកាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀងឡើយ និង (iii) អំឡុងពេលរាប់ចាប់ពីថ្ងៃទីមួយនៃខែនៃកាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀងរហូតដល់កាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀងនោះពិតប្រាកដ។

«**ថ្ងៃធ្វើការ**» មានន័យថាថ្ងៃផ្សេងក្រៅពីថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកស្របច្បាប់ដែលកំណត់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា ឬដែលមិនមែនជាថ្ងៃដែលធនាគារពាណិជ្ជនៅក្នុងប្រទេសកម្ពុជាបិទទ្វារមិនធ្វើការ។

«**ការទាមទារ**» ដែលពាក់ព័ន្ធនឹងបុគ្គលណាក៏ដោយ មានន័យថាបណ្តឹង ទណ្ឌកម្ម នីតិវិធីតុលាការ ការទាមទារ ការវាយតម្លៃ សេចក្តីសម្រេចតុលាការ សំណងខូចខាត ធនទណ្ឌ ប្រាក់ពិន័យ បំណុល ការតម្រូវ ចំណាយហោប៉ៅផ្ទាល់ខ្លួនក្នុងកម្រិតសមហេតុផលទោះក្នុងរូបភាពអ្វីក៏ដោយ (រួមបញ្ចូលថ្លៃចំណាយ និងសោហ៊ុយមេធាវី) និងការខាតបង់ដែលកើតមានចំពោះ ឬទទួលរងដោយបុគ្គលនោះ ប៉ុន្តែមិនរាប់បញ្ចូលការខាតបង់ផលចំណេញ ឬសំណងខូចខាតដែលមានលក្ខណៈពិសេស ចៃដន្យ ប្រយោល ជាទណ្ឌកម្មបន្ថែម ឬជាវិបាកតគ្នាដែលបុគ្គលនោះបានទទួលរងឡើយ។

«**ព័ត៌មានសម្ងាត់**» មានន័យថាចំណេះដឹង ព័ត៌មាន ឬជំនាញទាក់ទងនឹងអាជីវកម្ម ប្រព័ន្ធ អតិថិជន ទ្រព្យសម្បត្តិធនធាន ឬកិច្ចការជំនួញរបស់ភាគីណាមួយដែលបានបង្ហាញ ប្រាប់ ឬប្រគល់ជូនភាគីមួយទៀតក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ និង/ឬដែលភាគីមួយទៀតនោះបានដឹង ឬកាន់កាប់ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនោះ ហើយដែល ៖

(ក) ភាគីមួយទៀតដែលទទួលព័ត៌មាននោះមិនបានដឹងពីវានាពេលកន្លងមក

(ខ) មិនមែនជាប្រភេទព័ត៌មានដែលសាធារណជនទូទៅអាចដឹងឮ មិនថាមុន ឬក្រោយពេលផ្តល់ព័ត៌មានសម្ងាត់នេះស្របតាមការអនុវត្តកិច្ចព្រមព្រៀងនេះ ហើយដោយមិនជាប់ពាក់ព័ន្ធនឹងកំហុសរបស់ភាគីទទួលព័ត៌មាននោះ ឬ

(គ) ភាគីទទួលព័ត៌មានទទួលបានវានៅពេលក្រោយមកពីប្រភពណាមួយដែលភាគីនោះខ្លួនឯងដឹងថា ប្រភពនោះមានកាតព្វកិច្ចចំពោះមុខភាគីមួយទៀតក្នុងការរក្សាភាពសម្ងាត់នៃឯកសារ និងព័ត៌មានអស់នោះ។

«**ថ្លៃតំណ**» មានន័យថាប្រាក់ដែលអ្នកផ្តល់សេវាទឹកស្អាតរាយត្រូវបង់ជូន អ្នកផ្តល់សេវាទឹកដុំ ស្របតាមខ្លឹមសារនៃប្រការ ១២.១. (ថ្លៃតំណ)។

«**ទឹកត្រូវផ្គត់ផ្គង់**» មានន័យថាទឹកដែលអ្នកផ្ដល់សេវាទឹកដុំ ត្រូវផ្គត់ផ្គង់ជូនអ្នកផ្ដល់សេវាទឹកស្អាតរាយ ស្របតាមការកំណត់នានាដូចបង្ហាញក្នុងឧបសម្ព័ន្ធទី៥ (ព័ត៌មានពិស្ដារនៃទឹកត្រូវផ្គត់ផ្គង់) នៃកិច្ចព្រមព្រៀងនេះ។

«**ថ្ងៃ**» មានន័យថាអំឡុងពេល២៤ម៉ោងដែលចាប់ផ្ដើម និងចប់នៅពាក់កណ្ដាលអធ្រាត្រគិតតាមម៉ោងទីក្រុងភ្នំពេញ។

«**ការជូនដំណឹងពីការមិនអនុវត្តកិច្ចព្រមព្រៀង**» មានន័យដូចកំណត់ក្នុងប្រការ១៦.២.(ក)។

«**ចំណុចប្រគល់**» មានន័យថាចំណុចដូចបង្ហាញក្នុងឧបសម្ព័ន្ធទី២ (ចំណុចប្រគល់) ដែលជាចំណុចទឹកត្រូវផ្គត់ផ្គង់ភ្ជាប់ចូលប្រព័ន្ធរបស់អ្នកផ្ដល់សេវាទឹកស្អាតរាយ ។

«**ប្រាក់កក់**» មានន័យថាប្រាក់កក់ដែលអ្នកផ្ដល់សេវាទឹកស្អាតរាយ ត្រូវបង់ជូនអ្នកផ្ដល់សេវាទឹកដុំ តាមខ្លឹមសារនៃប្រការ ១២.២. (ប្រាក់កក់)។

«**កាលបរិច្ឆេទចាប់មានអានុភាព**» មានន័យថាកាលបរិច្ឆេទសរសេរបង្ហាញដំបូងគេនៅផ្នែកខាងលើនេះ ឬកាលបរិច្ឆេទផ្សេងទៀតតាមការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់គូភាគី។

«**ហេតុការណ៍បន្ទាន់**» មានន័យថាហេតុការណ៍ដែលបង្កផលប៉ះពាល់អវិជ្ជមានលើភាគីណាមួយហើយដែលកើតឡើងក្រៅស្ថានភាពប្រតិបត្តិការធម្មតា ឬដែលមិនអាចព្យាករបាន។

«**ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀង**» មានន័យថាករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្ដល់សេវាទឹកដុំ ឬករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្ដល់សេវាទឹកស្អាតរាយ ។

«**បរិក្ខារ**» មានន័យថាបរិក្ខារប្រព្រឹត្តិកម្មទឹក ប្រព័ន្ធបញ្ជូនទឹក និងការរៀបចំផ្សេងទៀតដែលបម្រើដល់សកម្មភាពផ្គត់ផ្គង់ទឹករបស់ភាគី។

«**ឧបករណ៍វាស់ចរន្តហូរទឹក**» មានន័យថាឧបករណ៍បំពាក់នៅចំណុចប្រគល់ដែលប្រើប្រាស់សម្រាប់វាស់ចរន្តហូរទឹកដែលត្រូវផ្គត់ផ្គង់ជូនអ្នកផ្ដល់សេវាទឹកស្អាតរាយ ។

«**ហេតុការណ៍ប្រធានសក្តិ**» មានន័យថាហេតុការណ៍ដែលហួសពីការគ្រប់គ្រង់របស់ភាគី ហើយដែលមិនអាចបញ្ចៀសបានបើទោះជាខ្លួនខិតខំយកចិត្តទុកដាក់ក៏ដោយ រួមមានជាអាទិ៍ គ្រោះធម្មជាតិដូចជា ទឹកជំនន់ អគ្គីភ័យ គ្រោះឧត្បាត សង្គ្រាម វិច្ឆេទកម្ម កុប្បកម្ម និងការបះបោរ។

«**វិក្កយបត្រ**» មានន័យថាវិក្កយបត្រដែលអ្នកផ្ដល់សេវាទឹកដុំ ចេញជូនអ្នកផ្ដល់សេវាទឹកស្អាតរាយ បន្តស្របតាមខ្លឹមសារនៃប្រការ ១២.៤. (វិក្កយបត្រ)។

«**សំណងព្រាងទុក**» មានន័យថាសំណងព្រាងទុកដែលគណនាស្របតាមខ្លឹមសារនៃប្រការ ១០.២. (ប្រាក់ពិន័យសំណងដែលអ្នកផ្ដល់សេវាទឹកដុំត្រូវបង់)។

«**បរិមាណអតិបរមា**» មានន័យថាបរិមាណអតិបរមានៃទឹកត្រូវផ្គត់ផ្គង់ដែលអ្នកផ្ដល់សេវាទឹកដុំ ត្រូវផ្ដល់ជូនអ្នកផ្ដល់សេវាទឹកស្អាតរាយ រៀងរាល់ខែ។

«**បរិមាណអប្បបរមាប្រចាំថ្ងៃ**» មានន័យថាបរិមាណអប្បបរមានៃទឹកត្រូវផ្គត់ផ្គង់ដែលអ្នកផ្តល់សេវាទឹកដុំត្រូវផ្តល់ជូនអ្នកផ្តល់សេវាទឹកស្អាតរាយ រៀងរាល់ថ្ងៃ។

«**បរិមាណអប្បបរមា**» មានន័យថាបរិមាណអប្បបរមានៃទឹកត្រូវផ្គត់ផ្គង់ដែលអ្នកផ្តល់សេវាទឹកដុំ ត្រូវផ្តល់ជូនអ្នកផ្តល់សេវាទឹកស្អាតរាយ បន្តរៀងរាល់ខែ។

«MISTI» មានន័យថា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

«**កាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ**» មានន័យថាកាលបរិច្ឆេទដែល អ្នកផ្តល់សេវាទឹកដុំចាប់ផ្តើមផ្គត់ផ្គង់ទឹកជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ស្របតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

«**ភាគី**» មានន័យថាអ្នកផ្តល់សេវាលក់ទឹកដុំ ឬអ្នកផ្តល់សេវាទឹកស្អាតរាយ ដោយគិតតាមករណីនីមួយៗ ហើយពាក្យ «គូភាគី» វិញវាក្តោបទាំងអ្នកផ្តល់សេវាទឹកដុំ និងអ្នកផ្តល់សេវាទឹកស្អាតរាយ ។

«**អត្រាប្រាក់ពិន័យ**» មានន័យដូចកំណត់ក្នុងប្រការ ១២.៧.។

«**ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំតាមការគ្រោងទុក**» មានន័យថាតំហែទាំ ការផ្លាស់ប្តូរ ឬការធ្វើសេវាកម្មបរិក្ខារជាប្រក្រតី ឬសកម្មភាពតំហែទាំផ្សេងទៀតតាមគម្រោង ឬកាលវិភាគរៀបចំទុកជាមុន។

«**ឧបករណ៍វាស់សម្ពាធ**» មានន័យថានាឡិកាបំពាក់នៅចំណុចប្រគល់ ដែលប្រើប្រាស់សម្រាប់វាស់សម្ពាធទឹកត្រូវផ្គត់ផ្គង់ជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ។

«**ទឹកឆៅ**» មានន័យថាទឹកដែលយកមកពីប្រភពដើមរបស់វា ហើយដែលមិនទាន់ឆ្លងកាត់ដំណាក់កាលប្រព្រឹត្តិកម្មនៅឡើយ។

«**ផែនការកែតម្រូវ**» មានន័យដូចកំណត់ក្នុងប្រការ ១៦.២.(គ)។

«**អ្នកផ្តល់សេវាទឹកស្អាតរាយ**» មានន័យដូចបង្ហាញនៅផ្នែកខាងលើនៃកិច្ចព្រមព្រៀងនេះ។

«**ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ**» សំដៅករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងដូចកំណត់ក្នុងប្រការ ១៥.២.។

«**ភាគីខាងអ្នកផ្តល់សេវាទឹកស្អាតរាយ**» មានន័យថាអ្នកផ្តល់សេវាទឹកស្អាតរាយ និងទេសាភិបាល មន្ត្រី និយោជិត អ្នកតំណាង ភ្នាក់ងារ ទីប្រឹក្សា អ្នកម៉ៅការគម្រោង ឬអ្នកទទួលអាជ្ញាប័ណ្ណរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ ក៏ដូចជាទេសាភិបាល មន្ត្រី និងនិយោជិតរបស់អ្នកទាំងនោះ រៀងៗខ្លួន។

«**ប្រព័ន្ធរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ**» មានន័យថាបណ្តាញទុយោបញ្ជូន និងចែកចាយទឹកស្អាតរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ រួមបញ្ចូលទាំងទឹកធ្វើប្រព្រឹត្តិកម្មរួចដែលភ្ជាប់ចូលប្រព័ន្ធរបស់អ្នកផ្តល់សេវាទឹកស្អាតរាយ នៅចំណុចប្រគល់។

«**ថ្លៃសេវាកម្ម**» មានន័យថាថ្លៃទឹកត្រូវផ្គត់ផ្គង់ដែលអ្នកផ្តល់សេវាទឹកស្អាតរាយត្រូវបង់ជូនអ្នកផ្តល់សេវាលក់ទឹកដុំ ។

«**ថ្លៃលក់ទឹក**» មានន័យថា ថ្លៃលក់ទឹកដែលអ្នកផ្តល់សេវាលក់ទឹកដុំ ផ្គត់ផ្គង់ទឹកជូនអ្នកផ្តល់សេវាទឹកស្អាតរាយ ហើយដែលកំណត់ដោយMISTIតាមកាលវេលានីមួយៗ។ ថ្លៃលក់ទឹក បច្ចុប្បន្នគឺដូចបង្ហាញក្នុងឧបសម្ព័ន្ធទី៦ (ថ្លៃលក់ទឹក)។

«**បិរវេលា**» មានន័យដូចកំណត់ក្នុងប្រការ ២.១.។

«**ការជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀង**» មានន័យដូចកំណត់ក្នុងប្រការ ១៦.២.(ឃ)។

«**អ្នកផ្តល់សេវាលក់ទឹកដុំ**» មានន័យដូចបង្ហាញនៅផ្នែកខាងលើនៃកិច្ចព្រមព្រៀងនេះ។

«**ករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀងរបស់អ្នកផ្តល់សេវាលក់ទឹកដុំ**» សំដៅករណីនៃការមិនអនុវត្តកិច្ចព្រមព្រៀង ដូចកំណត់ក្នុងប្រការ ១៥.១.។

«**កាលបរិច្ឆេទបញ្ចប់កិច្ចព្រមព្រៀង**» មានន័យថាកាលបរិច្ឆេទនៃការកើតមានស្ថានភាពណាមួយដូចខាងក្រោមនេះ ៖

(ក) ការបញ្ចប់កិច្ចព្រមព្រៀងនេះស្របតាមខ្លឹមសារនៃប្រការ១៦.១. (ការបញ្ចប់កិច្ចព្រមព្រៀង) ឬ

(ខ) ដល់គម្រប់ [១០] [(ដប់)] ឆ្នាំនៃកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការ។

«**ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំដែលមិនបានគ្រោងទុកមុន**» មានន័យថាតំហែទាំ ការផ្លាស់ប្តូរ ឬការធ្វើសេវាកម្មបរិក្ខារ ឬសកម្មភាពតំហែទាំផ្សេងទៀតដែលមិនបានគ្រោង ឬរៀបចំកាលវិភាគទុកជាមុនតាមខ្លឹមសារនៃប្រការ ១១.២. (ការផ្អាកប្រតិបត្តិការដើម្បីធ្វើតំហែទាំតាមការគ្រោងទុក)។

«**ភាគីខាងអ្នកផ្តល់សេវាលក់ទឹកដុំ**» មានន័យថាអ្នកផ្តល់សេវាទឹកដុំ និងទេសាភិបាល មន្រ្តី និយោជិត អ្នកតំណាង ភ្នាក់ងារ ទីប្រឹក្សា អ្នកម៉ៅការគម្រោង ឬ អ្នកទទួលអាជ្ញា ប័ណ្ណរបស់អ្នកផ្តល់សេវាលក់ទឹកដុំ ក៏ដូចជាទេសាភិបាល មន្រ្តី និង និយោជិតរបស់អ្នកទាំងនោះរៀងៗខ្លួន។

# ឧបសម្ព័ន្ធទី២ - ចំណុចប្រគល់

# ឧបសម្ព័ន្ធទី៣ - បរិមាណ

| ខែ | បរិមាណអប្បបរមា<br>(ម៉ែត្រគូបក្នុងមួយខែ) | បរិមាណអប្បបរមាប្រចាំថ្ងៃ<br>(ម៉ែត្រគូបក្នុងមួយថ្ងៃ) | បរិមាណអតិបរមា<br>(ម៉ែត្រគូបក្នុងមួយខែ) |
|---|---|---|---|
| មករា | | | |
| កុម្ភៈ | | | |
| មីនា | | | |
| មេសា | | | |
| ឧសភា | | | |
| មិថុនា | | | |
| កក្កដា | | | |
| សីហា | | | |
| កញ្ញា | | | |
| តុលា | | | |
| វិច្ឆិកា | | | |
| ធ្នូ | | | |
| **សរុប** | | | |

# ឧបសម្ព័ន្ធទី៤ - សម្ពាធទឹក និងចរន្តរំហូរទឹក

## ១. សម្ពាធទឹកសម្រាប់ប្រតិបត្តិការធម្មតា

| កម្រិតHGLអប្បបរមា (ខ្នាតម៉ែត្រAHD) | កម្រិតHGLអតិបរមា (ខ្នាតម៉ែត្រAHD) |
|---|---|
| [បញ្ចូល] | [បញ្ចូល] |

# ឧបសម្ព័ន្ធទី៥ - គុណភាពទឹកត្រូវផ្គត់ផ្គង់

# ឧបសម្ព័ន្ធទី៦ - ថ្លៃលក់ទឹក

## ឧបសម្ព័ន្ធទី៧ - ស្តង់ដានាឡិកា និងឧបករណ៍ផ្សេងទៀត